**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌ
# និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឡុង សុវណ្ណមុន្នីរ័ត្ន**

ណែនាំដោយ

លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៩

ជំនាន់ទី ២៣

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌ
# និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឡុង សុវណ្ណមុន្នីរ័ត្ន**

ណែនាំដោយ

លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ឡុង សុវណ្ណមុន្នីរ័ត្ន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៩-២០២៣ ជំនាន់ទី២៣។

**នាងខ្ញុំសូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

**អ្នកម្តាយ កែវ ចិន្តា** ជាទីគោរព ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងដល់រូបកូន ទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាងដែលមាននូវមហាឧបការគុណដ៏ឧត្តុមឧត្តមនិងធំធេងបំផុត គ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកជាអ្នកមានគុណបានផ្តល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅដល់រូបកូន ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូនចាប់តាំងពីថ្ងៃដែលកូននៅក្នុងផ្ទៃម្តាយរហូតដល់ពេញវ័យ ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ លោកអ្នកមានគុណបានអប់រំ ណែនាំ ទូន្មានប្រៀនប្រដៅកូន ឱ្យចេះដឹងល្អខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម និងសម្ភារៈរហូតដល់កូនបានបញ្ចប់ការសិក្សានេះដោយទទួលបាន ជោគជ័យ។ សូមជូនពរ អ្នកម្តាយមានសុខភាពល្អ អាយុយឺនយូរ ជៀសផុតពីជម្ងឺ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងជួយតម្រង់ទិសនាងខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាល់មូលដ្ឋានរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមវិជ្ជាជីវៈ។

សូមថ្លែងអំណរគុណ **លោក ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យដឹកនាំ បង្ហាត់បង្ហាញនូវគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទដោយបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់និង ផ្តល់ជាគំនិតក្នុងការជួយដោយអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ គ្រប់គ្រងជួយសម្រួលយ៉ាងចិត្តទុកដាក់រហូតធ្វើសារណានេះបានលេចចេញជារូបរាង។

ជាទីបញ្ចប់នាងខ្ញុំសង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណ ដែលបានជួយជ្រោមជ្រែងដល់នាងខ្ញុំ ជាពិសេសសូមប្រសិទ្ធពរជ័យសិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានការជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ ឆ្នាំកន្លងមកដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពីលោក លោកស្រី សាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យនាងខ្ញុំត្រូវបានលើកទឹកចិត្ត និង ទទួលការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "**ការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**"

` ប្រធានបទមួយនេះ គឺកើតឡើងចេញពីចម្ងល់ និងការចង់ដឹងឲ្យកាន់តែស៊ីជម្រៅរបស់យើងខ្ញុំទៅលើកិច្ចការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់នីតិជន និង អនីតិជន។ កិច្ចការស្រាវជ្រាវនេះផ្ដោតសំខាន់ទៅលើសិទ្ធិ និងករណីកិច្ចរបស់ នីតិជន និង អនីតិជនក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ព្រមជាមួយនឹង នីតិវិធីអនុវត្តទៅលើនីតិជន និង អនីតិជនដែលធ្វើយ៉ាណាធានាដល់ឧត្តមប្រយោជន៍របស់នីតិជន និង អនីតិជន។ លើសពីនេះទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងក៏ដោយសារមានការជួយជ្រោមជ្រែងណែនាំតម្រង់ទិសពីសំណាក់ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលលោកសាស្ត្រាចារ្យ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់នាងខ្ញុំ។

ថ្វីបើនាងខ្ញុំ បានធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចមកហើយក្ដីក៏កំហុសឆ្គងនៅតែអាចនឹងកើតមានឡើងជាពុំខាន។ ដូចនេះ សូមធ្វើការអភ័យទោសនូវរាល់កំហុងឆ្គងដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះហើយក៏រងចាំទទួលនូវការរិះគន់ និង ការកែលម្អក្នុងន័យស្ថាបនា ដើម្បីអាចធ្វើឲ្យស្នាដៃបន្តបន្ទាប់ទៀតកាន់តែមាននូវភាពល្អប្រសើរឡើង។

នៅទីបញ្ចប់ ក្នុងនាមនាងខ្ញុំជាអ្នករៀបរៀងសារណានេះឡើង ក៏សង្ឃឹមថាឯកសារមួយនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទានព្រមទាំងផ្ដល់ជាចំណេះដឹងបន្ថែមទៀត សម្រាប់ជាគន្លឹះ និងជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្តបាន។ ហើយនាងខ្ញុំ ក៏សូមជូនពរដល់អស់លោក លោកស្រីដែលកំពុងអានសៀវភៅមួយនេះ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**..........១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**

**១.១. គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ**..........៤

១.១.១. គោលការណ៍នីត្យានុកូលភាព..........៤

១.១.១.១. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស..........៥

១.១.១.២.គោលការណ៍នីត្យានុកូលភាពនៃទោស..........៥

១.១.២. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ..........៦

១.១.២.១. គោលការណ៍ឯកត្តកម្មនៃទោស..........៦

១.១.២.២. គោលការណ៍ឯកត្តកម្មនៃការប្រកាសទោស..........៧

**១.២. ធាតុផ្សំនៃបទល្មើស**..........៨

១.២.១. ធាតុនីត្យានុកូល..........៨

១.២.២. ធាតុសន្យានុម័ត..........៩

១.២.៣. ធាតុអត្តនោម័ត..........១១

**ជំពូកទី២**

**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**

**២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន**..........១៣

២.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ..........១៣

២.១.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ..........១៤

២.១.២. ទោសដែលត្រូវអនុវត្តចំពោះនីតិជន..........១៤

២.១.២.១. ប្រភេទនៃបទល្មើស..........១៥

ក. បទល្មើសជាបទឧក្រិដ្ឋ..........១៥

ខ. បទល្មើសជាបទមជ្ឈិម..........១៥

គ. បទល្មើសជាបទលហុ..........១៦

**២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**..........១៧
២.២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន..........១៧
២.២.១.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស..........១៧
២.២.១.២. កាលៈទេសៈនៃបទល្មើស..........១៩
២.២.១.៣. បុគ្គលិលក្ខណៈរបស់អនីតិជន..........២០
២.២.២. ការអនុវត្តទោសចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ..........២១
២.២.២.១. ទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំដល់ក្រោម១៨ឆ្នាំ..........២២
២.២.២.២. ប្រភេទនៃទោស..........២៣
ក.មូលទោស..........២៣
ខ.ទោសបន្ថែម..........២៤
គ.ទោសជំនួស..........២៩
២.២.២.៣. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន..........៣១
២.២.២.៤. ស្ថានសម្រាលទោសចំពោះអនីតិជន..........៣២
២.២.៣.៥. ការអនុវត្តទោសដាក់ពន្ធនាគារ..........៣២
២.២.៣.៦.កាអនុវត្តទោសពិន័យចំពោះអនីតិជន..........៣៤

## ជំពូកទី៣

## ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

**៣.១. មូលហេតុវិបល្លាសស្មារតី**..........៣៧
៣.១.១. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយមូលហេតុវិបល្លាសស្មារតី..........៣៧
៣.១.១.១.មានវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវ..........៣៧
៣.១.១.២. មានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ..........៣៧
៣.១.១.៣.មានវិបល្លាសស្មារតីដោយប្រើសារជាតិដែលច្បាប់បានហាមឃាត់..........៣៨
**៣.២. មូលហេតុស្តីពីអំពើយុត្តិកម្ម**..........៣៨
៣.២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ..........៣៩
៣.២.២. ការការស្រេបច្បាប់..........៤០
៣.២.៣. ស្ថានភាពចាំបាច់..........៤០
៣.២.៤. អានុភាពនៃកម្លាំងបង្ខំ..........៤០

**សេចក្តីសន្និដ្ឋាន**......................................................................................................៤២
**អនុសាសន៍**......................................................................................................៤៣
**ឯកសារយោង**
**ឧបសម្ព័ន**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅនៅលើពិភពលោកយើងនេះប្រជាជនក្នុងប្រទេសនីមួយៗតែងតែមានការប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលអាចបង្កឡើងដោយចេតនា ឬអចេតនាមិនថាបុគ្គលនោះស្ថិតនៅក្នុងវ័យណានោះទេ សិតសឹងតែមិនអាចជៀសផុតបានឡើងគ្រាន់តែពេលខ្លះអំពើទាំងនោះវាអាចមិនមានជាបញ្ហាធ្ងន់ធ្ងរ ឬវាអាចជាបញ្ហាធ្ងន់ធ្ងរ ដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គមជាតិ។ លើសពីនេះទៅទៀត ទោះបីជាក្នុងសង្គមយើងបច្ចុប្បន្នមិនថាបុគ្គលនោះក្នុងឋានៈណាក៏ដោយ ក៏នៅតែមានបុគ្គលមួយចំនួនបានបង្កភាពអសន្តិសុខ និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គមជាតិ ដែលជាមូលហេតុមួយនាំឲ្យប្រទេសនីមួយៗនៅលើពិភពលោកយើងនេះ ត្រូវបង្កើតឲ្យមានច្បាប់សម្រាប់ទប់ស្កាត់ពេលមានភាពអសន្តិសុខនៅក្នុងសង្គមនិងផ្តន្ទាទោសទៅលើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់សង្គម។

ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា បានបង្កើតឲ្យមាននូវច្បាប់ព្រហ្មទណ្ឌដែលជាច្បាប់សម្រាប់ទប់ស្កាត់ពេលមានភាពអសន្តិសុខនៅក្នុងសង្គម និងផ្តន្ទាទោសទៅលើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់សង្គម។ ច្បាប់ព្រហ្មទណ្ឌនៃប្រទេសកម្ពុជា អាចថាជាគោលការណ៍មួយប្រភេទ ដែលអាចប្រើប្រាស់សម្រាប់ដាក់ទោសដល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់សង្គម ឬប្រព្រឹត្តផ្ទុយពីបទបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាហើយជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បើជនណាបានប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់ជនណាមួយ នោះគឺត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ទៅតាមអំពើប្រព្រឹត្តរបស់ខ្លួនដោយមិនអាចផ្ទេរឲ្យអ្នកដទៃទទួលជំនួសបានឡើយនិងជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តអំពើរបស់ខ្លួន ឲ្យទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌទេ ព្រោះការយល់ដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តអំពើរបស់ខ្លួន គឺជាកត្តាមួយដែលនាំឲ្យបុគ្គលម្នាក់ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

នៅពេលមានបុគ្គលណាមួយ នៅក្នុងសង្គមបានប្រព្រឹត្តបទល្មើសកើតឡើងគឺតម្រូវឲ្យមានអ្នកចូលខ្លួនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាល់របស់ខ្លួនដែលស្របតាមអ្វីដែលច្បាប់បានកំណត់ យើងអាចនិយាយបានថាការទទួលខុសត្រូវព្រហ្មទណ្ឌ ជាច្បាប់ដែលបានតាក់តែងឡើងនេះគឺពិតជាផ្តល់គុណសម្បត្តិធំធេងឥតគណនាសម្រាប់សង្គមខ្មែរក៏ដូចជាពិភពលោកទាំងមូល។ ការទទួលខុសត្រូវព្រហ្មទណ្ឌជាផ្នែកច្បាប់មួយដែលបានអនុម័តឡើងដើម្បីដោះស្រាយបញ្ហាជាច្រើននៅក្នុងសង្គមខ្មែរ។ រាល់រូបវន្តបុគ្គល ដែលមានរូបរាងនៅក្នុង

សង្គមតែងបង្កើតជាបញ្ហាដោយចេតនា និងអចេតនានៃបញ្ហាសង្គមរបស់អ្នកសិក្សាស្រាវជ្រាវច្បាប់ក្នុងសង្គមខ្មែរទាំងមូលបានបង្កឲ្យមានការតាក់តែងច្បាប់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះឡើងដើម្បីដោះស្រាយបទល្មើសគ្រប់ប្រភេទដែលកើតមាន។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

គោលការណ៍នៃបទបញ្ញត្តិច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបើជនណាបានប្រព្រឹត្តនូវអំពើ ឬកំហុសខុសឆ្គងដែលបានបង្កឲ្យមានភាពប៉ះពាល់ដល់សង្គមជនទាំងនោះ ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌទៅតាមអំពើប្រព្រឹត្តរបស់ខ្លួនដោយមិនអាចផ្ទេរឲ្យអ្នកដទៃទទួលជំនួសបានឡើយ និងជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌទេ។ ដូច្នេះចំពោះបញ្ហាថាតើការទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈយ៉ាងណា? តើការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិជន និង អនីតិជនយ៉ាងដូចម្តេច? តើការអនុវត្តទោសព្រហ្មទណ្ឌមានលក្ខណៈដូចម្តេច? តើការសិក្សាស្រាវជ្រាវអំពីការទទួលខុសត្រូវព្រហ្មទណ្ឌមានផលប្រយោជន៍អ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការស្វែងយល់ អំពីបែបបទនៃការទទួលខុសត្រូវទោសព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ របស់ជនដែលបានប្រព្រឹត្តអំពើល្មើស និងបញ្ញត្តិច្បាប់ក្នុងក្រមព្រហ្មទណ្ឌ ក្នុងនាមដែលជនល្មើសជា នីតិជន ឬ អនីតិជនអាចឲ្យយល់បានថាអំពើ ឬ ទង្វើមួយចំនួនដែលក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារបន្ថែមដើម្បីសរសេរសារណាមួយនេះឡើងមក។ ក្នុងនោះរួមមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតដូចដែលបានលើកឡើងនៅក្នុងឯកសារយោង។ នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរយើងខ្ញុំសូមផ្តោតតែទៅលើច្បាប់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវនៃប្រធានបទនេះ យើងជ្រើសរើសយកតែការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ យកមកសិក្សា និងវិភាគ។ ជាងនេះទៅទៀតយើងក៏អាច

លើកច្បាប់ផ្សេងទៀត របស់ខ្មែរយើងដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌដើម្បីធ្វើការបញ្ចូលគ្នាឲ្យមានភាពរលូន និងភាពច្បាប់លាស់ក្នុងការបកស្រាយតាមរយៈការវិភាគទិន្នន័យច្បាប់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

ការរៀបចំតាក់តែងនូវសារណានេះឡើងក្នុងគោលបំណង ចងក្រង ប្រមូលឯកសារច្បាប់ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ជាឯកសារច្បាប់ដែលមានចែងជាធរមាន។ លើសពីនេះទៀតយើងសិក្សា និងវិភាគទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឲ្យបានកាន់តែស៊ីជម្រៅដើម្បីជាឯកសារដ៏សំខាន់មួយសម្រាប់សិស្សានុសិស្ស និស្សិត អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋដែលចង់ស្វែងយល់ពីការទទួលខុសត្រូវព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា។ ប្រធានបទនេះមានសារៈប្រយោជន៍ និងក្លាយជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកអានគ្រប់រូបព្រមទាំងដើម្បីទុកជាឯកសារដល់ សិស្សនិស្សិតជំនាន់ក្រោយៗអាចយល់ដឹងកាន់តែច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌនេះ បន្ថែមលើសនេះទៀតដើម្បីពង្រីកចំណេះដឹងផ្ទាល់ខ្លួន ព្រមទាំងចូលរួមចំណែកផ្តល់ជាអនុសាសន៍ខ្លះលើការអនុវត្តន៍ច្បាប់ខាងលើគ្រប់រូបវន្តបុគ្គលឲ្យមានប្រសិទ្ធិភាព តម្លាភាពពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌនៃព្រះរាជាណាចក្រ កម្ពុជា និងដើម្បីសង្គមជាតិទាំងមូល។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការរៀបចំតាក់តែងនូវសារណានេះឡើងក្នុងគោលបំណង ចងក្រង ប្រមូលឯកសារច្បាប់ពាក់ព័ន្ធត្រូវបានរៀបរៀងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពណ៌នា និង វិភាគ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វែងរកពត៌មាន និងដកស្រង់ចេញពីប្រភពល្អៗព្រមទាំងច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជាក៏ដូចជាឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី១៖ សញ្ញាណទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ជំពូកទី២៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

ជំពូកទី៣៖ កាមិនរទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

# ជំពូកទី១

# សញ្ញាណទូទៅនៃ

# ការទទួលខុសត្រូវព្រហ្មទណ្ឌ

# ជំពូកទី១

# សញ្ញាណទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

## ១.១. គោលការណ៍ទូទៅទាក់ទងនិងការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ទូទៅទាក់ទងនិងការទទួលខុសត្រូវព្រហ្មទណ្ឌដែលក្នុងច្បាប់ ចែងនូវគោលការណ៍ដ៏ធំៗ ដែលជាគោលការណ៍នេះយើងអាចចាត់ទុកថាគោលការណ៍គ្រឹះនេះ គឺត្រូវបានគេយល់បានថា គ្មានបទល្មើស គ្មានទោសបើគ្មានច្បាប់ចែង ដែលជាគោលការណ៍ទី១ គឺ គោលការណ៍នីត្យានុកូលភាព ។ គោលការណ៍ទី២ ជាមូលដ្ឋានទូទៅ ឬមួយក៏មូលដ្ឋានរួមតែម្តងទាក់ទងជាមួយគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ ពីព្រោះ ក្រមព្រហ្មទណ្ឌបានចែងនូវគោលការណ៍ដ៏ធំមួយដែលគោលការណ៍នេះ មានចែងកំណត់នៅក្នុងក្រមព្រហ្មទណ្ឌដែលឲ្យឈ្មោះថា គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលសំដៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន ។ ជាកិច្ចបន្តយើងនឹងពន្យល់ឲ្យបានក្បោះក្បាយអំពីគោលការណ៍ដែរយើងបានលើកឡើងខាងលើរួមមាន គោលការណ៍នីត្យានុកូលភាព គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចតទៅ ៖

### ១.១.១. គោលការណ៍នីត្យានុកូលភាព

គោលការណ៍នីត្យានុកូលភាពក្រមព្រហ្មទណ្ឌបានបញ្ជាក់យ៉ាងច្បាស់ថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសបាន។ មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេល ដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។ [1]

ឧទាហរណ៍៖ បុរស ក បានលួចទូរស័ព្ទបុរស ខ ដោយមូលហេតុ បុរស ក គ្មានប្រាក់បង់ថ្លៃផ្ទះជួលទើបធ្វើឲ្យបុរស ក សម្រេចចិត្តលួច។

គោលការណ៍នីត្យានុកូលភាពនេះមានចរិតជាបញ្ញត្តិគ្រឹះនៅក្នុងប្រព័ន្ធនៃនីតិព្រហ្មទណ្ឌតែម្តង ដោយហេតុថា ច្បាប់ព្រហ្មទណ្ឌ គឺបានបញ្ញត្តិដើម្បីបង្កើតនូវបញ្ជីនៃបទល្មើស មានន័យថាជាបញ្ជីនៃអំពើដែលសង្គមបានហាមឃាត់ និងបានបញ្ញត្តិដើម្បីបង្កើតនូវបញ្ជីនៃទោស ព្រមទាំងគោលការណ៍មួយចំនួនទាក់ទងដល់ការកំណត់អំពីទោស ក៏ដូចជាការអនុវត្តទោសផងដែរ។ គោលការណ៍នីត្យានុកូលភាពដែលគោលការណ៍នេះមានសារៈសំខាន់ណាស់នៅក្នុងប្រព័ន្ធនីតិសាស្ត្រ ជាពិសេសនោះសម្រាប់នីតិព្រហ្មទណ្ឌ គោលការណ៍នេះត្រូវបានបែងចែកជា ២ (ពីរ) គឺ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស។

[1] មាត្រា ៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

**១.១.១.១. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស**

នីត្យានុកូលភាពនៃបទល្មើសគឺសំដៅលើអំពើណាមួយ ដែលគេអាចចាត់ទុកថាជាបទល្មើស បាន លុះត្រាតែអំពើនោះមានចែងជាមុនយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នេះទេតុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាមានគោលការណ៍មួយកំណត់ថា គ្មានបទល្មើសណាដែលច្បាប់មិនបានចែងឡើយ។ នោះយើងអាចយល់បានថាគោលការណ៍នេះបានតម្រូវអោយច្បាប់ព្រហ្មទណ្ឌកំណត់អោយ បានច្បាស់លាស់នូវនិយមន័យនៃបទល្មើសនីមួយៗ ជាពិសេសគឺ សញ្ញាណដែលជាធាតុផ្សំ។

**១.១.១.២.គោលការណ៍នីត្យានុកូលភាពនៃទោស**

នីត្យានុកូលភាពនៃទោសបានន័យថា ដើម្បីយកទោសណាមួយទៅផ្តន្ទាលើជនណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូចនេះទេ គេមិនអាចអនុវត្តទោសទៅលើបុគ្គលណាម្នាក់បានឡើយ។ ដូចនេះគឺដាច់ខាតត្រូវតែតម្រូវអោយមានចែង ពីបទប្បញ្ញត្តិនៃទោស បើមិនដូច្នេះទេ ចៅក្រមមិនអាចប្រកាសលើជនណាមួយបានឡើយ គឺមិនអាចបង្កើតទោសទណ្ឌដោយខ្លួនឯងទេ ទោះបីជាច្បាប់បានកំណត់ថាអំពើនោះ ជាបទល្មើសក៏ដោយ។

ឧទាហរណ៍៖ ការមិនព្រមបង់អាហារកិច្ចនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវ ផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់អាហារកិច្ចនេះ មិនស្មោះត្រង់។[2]

ដូចនេះបើអំពើមិនព្រមបង់អាហារកិច្ចគឺជាបទល្មើសព្រហ្មទណ្ឌ ក៏ប៉ុន្តែមិនបានចែងកំណត់ ឬបញ្ញត្តិពីទោសទណ្ឌនៃបទល្មើសនេះឡើយ។ ដូចនេះអ្នកធ្វើអំពើនេះមិនត្រូវផ្តន្ទាទោសឡើយនាសម័យកាលនោះ ព្រោះច្បាប់បានកំណត់តែនីត្យានុកូលភាពនៃបទល្មើស តែមិនបានកំណត់នូវក្នុងគោលការណ៍នីត្យានុកូលភាពនៃទោស។ យើងពិនិត្យឃើញថានីត្យានុកូលភាពនៃទោស បានលិចឡើងសម្រាប់អំពើមិនព្រមបង់អាហារកិច្ចដែលត្រូវផ្តន្ទាទោសពី១ខែទៅ១ឆ្នាំនិងពិន័យជាប្រាក់ពី១០០.០០០(មួយសែន) ទៅ ២.០០០.០០០(ពីរលាន)រៀល។[3]

**១.១.២. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺ សំដៅការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះមានន័យថា បុគ្គលណាជាអ្នកប្រព្រឹត្តបទល្មើសបុគ្គលនោះជាអ្នកទទួលខុសត្រូវទោសព្រហ្មទណ្ឌមិនអាចឲ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលទោសជំនួសឡើយ ឬយើងអាចនិយាយយ៉ាងខ្លីងាយយល់ថា ក្នុងរឿងព្រហ្មទណ្ឌអ្នកណាប្រព្រឹត្តអ្នកនោះជាអ្នកទទួលខុសត្រូវទណ្ឌកម្មលើអំពើរបស់ខ្លួនឯង

[2] មាត្រា ៧៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

[3] មាត្រា ៣២៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ដែលបានប្រព្រឹត្តនោះ។ ទោះបីទោសនោះជាប្រភេទទោសអ្វីក៏ដោយ ប៉ុន្តែលើកលែងចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌ។[4] អំពើផ្ទាល់ខ្លួនមានន័យថាបើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ។

ករណីបែបនេះ គឺខុសពីរឿងក្តីរដ្ឋប្បវេណីមានន័យថា ក្នុងរឿងរដ្ឋប្បវេណីច្បាប់អនុញ្ញាតឲ្យអ្នកដទៃទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌអ្នកណាជាអ្នកប្រព្រឹត្តបទល្មើស អ្នកនោះគឺជាអ្នកទទួលខុសត្រូវ ដែលភាសាខ្មែរយើងនិយាយយ៉ាងសាមញ្ញថា អ្នកណាធ្វើ អ្នកនោះទទួល ហេតុនេះមិនអាចឲ្យអ្នកដទៃចូលទៅទទួលទោសជំនួសបានទេ ទោះបីទោសនោះជាទោសប្រភេទអ្វីក៏ដោយ។

ឧទាហរណ៍៖ មូលទោសគឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ប្រសិនបើជននោះត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ គឺច្បាប់មិនអនុញ្ញាតឲ្យអ្នកដទៃចូលទៅទទួលរងទោសជំនួសឲ្យទណ្ឌិតនោះទេ។ សូម្បីតែការបង់ប្រាក់ពិន័យក៏ច្បាប់មិនអនុញ្ញាតឲ្យអ្នកដទៃ ទៅបង់ប្រាក់ជំនួសដែរព្រោះគោលបំណងនៃទោសព្រហ្មទណ្ឌដែលមានគោលដៅធ្វើឲ្យជននោះខ្លាចអារ និងដើម្បីបង្ការដល់សាធារណជន។ ដូច្នេះការដាក់ទណ្ឌកម្ម គឺធ្វើឲ្យទណ្ឌិតមានអារម្មណ៍មួយទទួលរងថា អ្វីដែលគាត់ប្រព្រឹត្តនោះគឺខុស ។

#### ១.១.២.១. គោលការណ៍ឯកត្តកម្មនៃទោស

គោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺមានសញ្ញាណតាំងពីបុរាណកាលមក ហើយក្រមព្រហ្មទណ្ឌបច្ចុប្បន្ននេះបានបញ្ញត្តិអំពីគោលការណ៍ឯកត្តកម្មនៃទោស។ គោលការណ៍ឯកត្តកម្មនៃទោសគ្របដណ្តប់លើការប្រកាសទោសរបស់ចៅក្រម ដែលតម្រូវឲ្យចៅក្រមត្រូវពិចារណាឲ្យបានម៉ត់ចត់ទៅលើស្ថានភាព ដែលជាកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសបុគ្គលិកលក្ខណៈរបស់ជនល្មើសជាមុនសិន មុននឹងធ្វើការសម្រេចចិត្តប្រកាសទោសរបស់ជនជាប់ចោទនោះ។ ដោយយើងឃើញថាទោសដែលចៅក្រម ត្រូវសម្រេច ឬត្រូវប្រកាស ឬកំណត់សម្រាប់បុគ្គលនីមួយៗ ដោយតុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និង កាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះ។[5]
គោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺជាគោលការណ៍ដែលត្រូវបានបង្កើតឡើងទុកជាមូលដ្ឋានគ្រឹះដល់ចៅក្រមជំនុំជម្រះ ពិចារណាទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗ ដែលបានប្រព្រឹត្តបទល្មើសដើម្បីឈានទៅដល់ការប្រកាសទោសព្រហ្មទណ្ឌ។

[4]មាត្រា ២៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[5] មាត្រា ៩៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

គោលការណ៍ឯកត្តកម្មនៃទោសមានន័យថា ត្រូវថ្លឹងថ្លែងនូវគ្រោះថ្នាក់នៃបទល្មើសដែលកើតមានដោយសារអំពើល្មើស និងចរិកគ្រោះថ្នាក់របស់បុគ្គលនៅក្នុងការជ្រើសរើសយកទោសណាមួយ ដើម្បីដាក់ឲ្យត្រូវសមល្មមទៅតាមកម្រិតដែលគាត់បានប្រព្រឹត្ត។ ហើយពេលខ្លះច្បាប់ផ្តល់ជាសិទ្ធិអំណាចដល់គាត់យ៉ាងទូលំទូលាយក្នុងការចាត់ចែងថែមទៀតដោយឈរទៅលើមូលដ្ឋាន ឬឈរលើស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពសង្គម ចៅក្រមគាត់អាចចាត់ចែងអំពីទោសនោះបានទៀត ដែលចំណុចស្តីពីការចាត់ចែងនូវទោសនេះយើងនឹងលើកមកបកស្រាយលម្អិតអំពីបញ្ហានេះនាពេលខាងមុខបន្ទាប់ទៀត។

**១.១.២.២. គោលការណ៍ឯកត្តកម្មនៃការប្រកាសទោស**

តុលាការធ្វើការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និង កាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្តទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។ ជាគោលការណ៍មូលដ្ឋានដែលមានបញ្ញាតិនៃក្រមព្រហ្មទណ្ឌ សម្រាប់ចៅក្រមយកមកពិចារណអំពីស្ថានភាពរបស់ជនល្មើសក្នុងពេលប្រព្រឹត្តបទល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ពិចារណាអំពីចរិតលក្ខណៈ ឬ សភាពផ្លូវចិត្តរបស់ជនជាប់ចោទនិងទំហំព្យសនកម្មបង្កដល់ជនរងគ្រោះ និងសង្គមជាតិជាដើមមុននឹងធ្វើការប្រកាសទោសព្រហ្មទណ្ឌ។ មុននឹងធ្វើការសម្រេចអំពីការផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាជំរុញដែលនាំឲ្យមានបទល្មើស និងកិរិយាមារយាទក្រោយពេលប្រព្រឹត្តបទល្មើស ដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។

ផ្ទុយទៅវិញ បើការប្រកាសទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះលើទោសនឹងនាំឲ្យមានភាពលម្អៀង និងអយុត្តិធម៌។ ជាពិសេស គឺទាមទារឲ្យចៅក្រមនីមួយៗត្រូវស្វែងយល់ឲ្យបានច្បាស់លាស់ អំពីមូលដ្ឋាននៃគោលការណ៍នេះដើម្បីជៀសវាងការកំណត់ទណ្ឌកម្ម ឬប្រកាសទោសមិនសមហេតុផល។ ពោលគឺត្រូវធ្វើការប្រកាសទោស និងជ្រើសរើសរបបនៃការប្រកាសទោសឲ្យសាកសមនឹងបុគ្គលដែលបានប្រព្រឹត្តបទល្មើស។ គ្រប់ស្ថានភាពទាំងអស់ទាក់ទងនឹងការប្រកាសទោសគឺមន្ត្រីអនុវត្តច្បាប់ជាពិសេសចៅក្រមនៃតុលាការត្រូវពឹងផ្អែកទាំងស្រុងទៅលើគោលការណ៍គ្រឹះ។ នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យផង តុលាការអាចប្រកាស ទោសដាក់

ពន្ធនាគារ និង ទោសពិន័យជាមួយគ្នា ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ទោសពិន័យជាប្រាប់តែមួយប៉ុណ្ណោះ។[6]

## ១.២. ធាតុផ្សំនៃបទល្មើស

នៅពេលមានបទល្មើសមួយកើតឡើង ជនល្មើសត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននូវទង្វើដែលខ្លួនបានប្រព្រឹត្ត។ គ្រប់បទល្មើសទាំងអស់ដែលកើតឡើងដោយចេតនាក្តី ឬ អចេតនាក្តីគឺសុទ្ធសឹងតែមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ចូលរួម ទើបអាចបង្កើតបានជាបទល្មើសមួយ។ ប្រសិនបើគ្មានធាតុផ្សំនៃបទល្មើសចូលរួមគ្រប់គ្រាន់ទេនោះ មិនអាចចាត់ទុកថាអំពើនោះជាបទល្មើសបានទេ។ ធាតុផ្សំនៃបទល្មើសត្រូវបានចែកចេញជាបីប្រភេទគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំសន្យានុម័ត ឬធាតុផ្សំសម្ភារៈ និងធាតុផ្សំអត្តនោម័ត យោងតាមគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលណាប្រព្រឹត្តបុគ្គលនោះទទួលចំពោះតែអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ បទល្មើសក៏អាចត្រូវបានចាត់ទុកជាបាតុភូតអសកម្មក្នុងជីវភាពរស់នៅផងដែរ ព្រោះថាសកម្មភាពដែលជនល្មើសបានប្រព្រឹត្តវាបានធ្វើឲ្យមានការភ័យខ្លាចនឹងបង្កឲ្យមានភាពរញ៉េរញ៉ៃក្នុងសង្គម និងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

### ១.២.១. ធាតុផ្សំនីត្យានុកូល

ធាតុនីត្យានុកូល ឬហៅថាធាតុច្បាប់ មានន័យថាជាធាតុនៃបទល្មើសមួយដែលច្បាប់កំពុងមានជាធរមានចាត់ទុកអំពើណាមួយ ដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ថាជាបទល្មើស។ ធាតុនីត្យានុកូល គឺជាធាតុផ្សំទាក់ទងនឹងច្បាប់ហើយក៏ជាធាតុផ្សំដែលមានសារៈសំខាន់ ព្រោះថានៅក្នុងគោលគំនិតរបស់អ្នកច្បាប់គឺត្រូវមានច្បាប់ចែង។ រាល់បទល្មើសណាមួយដែលមានច្បាប់ចែងជា គោលការណ៍នីត្យានុកូលភាព។ ដែលអាចធ្វើការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ និងផ្តន្ទាទោសទៅលើបុគ្គលនោះបានលុះត្រាតែអំពើដែលប្រព្រឹត្តដោយបុគ្គលនោះ មានចែងយ៉ាងជាក់ច្បាស់នៅក្នុងច្បាប់ដែលកំពុងមានជាធរមាន ដែលនេះស្របទៅតាមគោលការណ៍នីត្យានុគោលភាព ដែលមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហទណ្ឌបាន។[7] ដូច្នេះមានន័យថា មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចប្រកាសបាន ហើយជាគោលការណ៍នេះមានន័យថា មានបទល្មើស គឺមានទោសបើមានច្បាប់ចែង ឬគ្មានបទល្មើស គឺគ្មានទោសបើគ្មានច្បាប់ចែង។ ដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបាន លុះត្រាតែមានច្បាប់ចែងច្បាស់លាស់

---

[6] មាត្រា ៩៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[7] មាត្រា ៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

និងមានការផ្តន្ទាទោសច្បាស់លាស់។ រាល់បទល្មើសណាមួយដែលមានច្បាប់ចែងជា គោលការណ៍នីត្យានុកូលភាព។

ឧទាហរណ៍១៖ ប្រសិនបើបុគ្គល **ក** យកកាំបិតទៅចាត់សម្លាប់បុគ្គល **ខ** ដោយសារមូលហេតុណាមួយនោះ នោះអំពើសម្លាប់មនុស្សរបស់បុគ្គល **ក** ជាបទល្មើសព្រហ្មទណ្ឌដែលជា "បទឃាតកម្ម" ដែលអំពើនេះនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំទៅ ១៥(ដប់ប្រាំ)ឆ្នាំ។[៨]

ឧទាហរណ៍២៖ ការសម្លាប់មនុស្សដោយកាត់ក្បាល កាត់ខ្លួនជាបំណែកងៗរួចដាក់ក្នុងថង់ហើយបានយកទៅបោះចោលនៅក្នុងទឹក ឬបោះចោលតាមទីតាំងផ្សេងៗ ។ ក្នុងករណីនេះចូលជាបទល្មើឃាតកម្ម ជាបទល្មើសមួយដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គឺជាអំពើសម្លាប់មនុស្សដោយចេតនាដោយប្រើអាវុធ ឬមិនប្រើអាវុធ។ ប៉ុន្តែប្រសិនបើបុគ្គលនោះសម្លាប់សត្វ គឺមិនអាចចោទប្រកាន់បុគ្គលនោះថាបានប្រព្រឹត្តបទល្មើសឃាតកម្មបានទេ ព្រោះថាប្រធាននៃបទល្មើសមិនត្រូវបានការពារដោយច្បាប់ព្រហ្មទណ្ឌ។

ឧទាហរណ៍៣៖ ប្រសិនបើបុគ្គល **ក** យកកាំបិតចុងស្រួចទៅចាក់សម្លាប់សត្វជ្រូកដែលបណ្តាលឲ្យជ្រូកនោះស្លាប់អំពើរបស់បុគ្គល **ក** នេះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ព្រោះច្បាប់មិនបានចែងហាមឃាត់ថាអំពើនេះថាជាបទល្មើសនោះទេ។

### ១.២.២. ធាតុសន្យានុម័ត

ធាតុផ្សំសន្យានុម័ត ឬយើងអាចធ្វើការហៅម្យ៉ាងទៀតថា ធាតុផ្សំសម្ភារៈសំដៅទៅលើអំពើរបស់បុគ្គលណាម្នាក់ទៅលើអង្គហេតុ ឬហេតុការណ៍ទាំងឡាយណាដែលបង្កឱ្យមានជាបទល្មើសណាមួយដល់មនុស្ស និងសង្គម។ នៅពេលជនណាមួយមានគំនិតផ្តួចផ្តើមមានបំណងប្រព្រឹត្តបទល្មើស ក៏ប៉ុន្តែបំណងរបស់គេនោះត្រូវបានស្ថិតនៅក្នុងអារម្មណ៍ នៅមានបំណងដែលសំដៅទៅលើអំពើវិជ្ជមាន ឬអំពើអវិជ្ជមានដែលប្រព្រឹត្តដោយបុគ្គលណាម្នាក់ ហើយស្តែងចេញជាសម្ភារៈមកខាងក្រៅទោះដោយអំពើសកម្មក្តី ឬ អំពើអកម្មក្តីដែលអំពើនោះបណ្តាលឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសេរីភាព បូរណភាពផ្លូវកាយ បូរណភាពផ្លូវចិត្ត និងទ្រព្យសម្បត្តិឯកជនជាដើម។ នៅក្នុងអំពើជាសត្យានុម័តនេះ គឺសំដៅលើអំពើទាំងឡាយដែលប្រព្រឹត្តក្រោមរូបភាពជាអំពើពីរប្រភេទ គឺអំពើសកម្ម និងអំពើអកម្ម។

- អំពើសកម្ម ឬបទល្មើសសកម្មជាបទល្មើសដែលមានធាតុផ្សំសត្យានុម័តជាសកម្មភាពវិជ្ជមាន ឬជាអំពើវិជ្ជមាន គឺជាអំពើដែលស្តែងចេញពីសកម្មនៃកាយវិការរបស់ចារីដែលមានន័យថា ចារីបានប្រព្រឹត្តអំពើចេញជាក់ស្តែងដែលអ្នកណាក៏មើលឃើញថាបុគ្គលនោះបានប្រព្រឹត្តបទល្មើសយ៉ាងស្ទិតស្ទាញដើម្បីសម្រេចនូវ

[៨] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

គោលបំណងរបស់ខ្លួន។ អំពើសកម្ម សំដៅទៅលើការសម្លាប់មនុស្សដោយផ្ទាល់ដូចជាការបាញ់កាំភ្លើង ការកាប់នឹងកាំបិត និយាយជារួមទៅ គឺជាការ ប្រព្រឹត្តសកម្មភាពដោយផ្ទាល់របស់អ្នកប្រព្រឹត្ត។

ឧទាហរណ៍៖ លោក **ក** បានយកដំបងមកវាយទៅលើក្បាលលោក **ខ** ដែលជាដៃគូវិវាទបណ្តាលឲ្យលោក **ខ** រងរបួសជាទម្ងន់។ នៅក្នុងករណីនេះធាតុសត្យានុម័តជាអំពើសកម្មគឺ ការយកដំបងទៅវាយទៅលើក្បាលលោក **ខ** ដែលបណ្តាលឲ្យរងរបួសជាទម្ងន់។

- អំពើអសកម្មវិញ គឺជាការបង្កឡើងដោយអំពើសត្យានុម័តជាសកម្មភាព អវិជ្ជមាន ឬអំពើអវិជ្ជមានដែលមានន័យថា ចារីមិនបានរាយការណ៍អំពីអំពើអ្វីមួយដែលច្បាប់តម្រូវឲ្យធ្វើដែលមានលក្ខណៈ ជាកាតាព្វកិច្ចទាំងដែលចារីមានបុគ្គលលក្ខណៈ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តកាតាព្វកិច្ចនោះ។ អំពើដែលជាកាតព្វកិច្ចនេះទាល់តែច្បាប់បានចែងយ៉ាងជាក់ច្បាស់ទុកជាមុនថា ប្រសិនបើមិនបំពេញនឹងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។

ឧទាហរណ៍៖ ការមិនប្ដឹងបរិហារពីការធ្វើបាប និងការបំពារបំពានផ្លូវភេទលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំក្រមព្រហ្មទណ្ឌ បានចែងថា "រាល់បុគ្គលណាដែលបានដឹងពីការធ្វើ ឬការបៀតបៀនខាងផ្លូវភេទលើអនីតិជនអាយុក្រោម១៥ ឆ្នាំហើយមិនប្តឹងបរិហាដល់អាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរតុលាការត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលដល់ ៦.០០០.០០០ (ប្រាំមួយលាន) រៀល"។[៩] ក៏ប៉ុន្តែប្រសិនបើបុគ្គលណាម្នាក់ មិនបានបំពេញកាតាព្វកិច្ចដែលបានកំណត់ដោយហេតុថាជននោះមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់ក្នុងការបំពេញបុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ឧទាហរណ៍៖ ការមិនជួយមនុស្សដែលកំពុងលង់ទឹកដោយមូលហេតុថាខ្លួនជាជនពិការជើងម្ខាង មិនអាចហែលទឹកបាននោះជនដែលស្ថិតក្នុងស្ថានភាពពិការនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

### ១.២.៣. ធាតុអត្តនោម័ត

និយមន័យធាតុផ្សំអត្តនោម័ត គឺជាកិរិយាផ្នត់គំនិតខាងក្នុងរបស់ជនល្មើស ឬឆន្ទៈរបស់ចារីក្នុងការប្រព្រឹត្តបទល្មើសដែលក្នុងនោះអាចជាកំហុសចេតនា ឬកំហុសអចេតនាចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គម ឬក៏អាចនិយាយម្យ៉ាងទៀតថាអំពើសត្យានុម័ត ដែលឆ្លើយតបទៅនឹងបទល្មើសអាចនឹងត្រូវទទួលរងនូវការផ្តន្ទាទោសបាន លុះត្រាតែចារីបានធ្វើសកម្មភាពដោយមានឆន្ទៈ ឬដោយដឹងខ្លួនថាបានបំពានច្បាប់ព្រហ្មទណ្ឌ។ អំពើជាធាតុសត្យានុម័តតែមួយពុំគ្រប់គ្រាន់ ដើម្បីបង្កើតបានជាបទល្មើសទេហើយការកំណត់បទល្មើសតែងតែផ្អែកលើកំហុសដែលកើតចេញពីចិត្តគំនិតរបស់ចារី។ កំហុសចេតនាសំដៅទៅលើចេតនាក្នុងការប្រព្រឹត្តបទល្មើស

[៩] មាត្រា ៥៣០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

មានឆន្ទៈក្នុងការប្រព្រឹត្តបទល្មើសដែលមានន័យថា ចារីបានដឹងថាអំពើរបស់ខ្លួនជាអំពើដែលច្បាប់ហាមឃាត់ ប៉ុន្តែចារីនៅតែព្យាយាមប្រព្រឹត្តដែលក្រមព្រហ្មទណ្ឌបានចែងថា "ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត"។[10]

ចេតនាក្នុងការប្រព្រឹត្តបទល្មើស ឬត្រូវបានគេហៅម្យ៉ាងទៀតថាជា ចេតនាតទុច្ចរិតមានច្រើនប្រភេទដូចជា ចេតនាទុច្ចរិតទូទៅ ចេតនាទុច្ចរិតពិសេស ចេតនាទុច្ចរិតធ្ងន់ធ្ងរ ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់ និងចេតនាទុច្ចរិតចំពោះ និង មិនចំពោះ។ ដូច្នេះ ដើម្បីបង្កើតឱ្យបានជាបទល្មើស ចារីត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស។ កំហុសអាចផ្អែកលើឆន្ទៈ ដែលមានទិសដៅច្បាស់លាស់ដោយ សំដៅទៅរកគោលដៅខុសច្បាប់ណាមួយ ពោលគឺចារីពិតជាមានឆន្ទៈ និង ដឹងពីលទ្ធផលខុសច្បាប់នៃអំពើរបស់ខ្លួនដែលគេហៅថា កំហុសចេតនា។ ក្នុងករណីខ្លះទៀត កំហុសសំដៅលើ ស្ថានភាពដែលមិនមានឆន្ទៈគ្រប់គ្រាន់ ឬការប្រុងប្រយ័ត្នគ្រប់គ្រាន់ ដើម្បីជៀសវាងនូវលទ្ធផលខុសច្បាប់ដែលគេ ហៅថា កំហុសអចេតនា។

ឧទាហរណ៍៖ **ក** និង **ខ** ជាមិត្តភក្តិនឹងគ្នាដោយសារតែគ្មានលុយទិញសម្ភារៈនិយម **ក** និង **ខ** ក៏សម្រេចចិត្តធ្វើសកម្មភាពឆក់កាបូបភ្ញៀវទេសចរណ៍ដើម្បីយកលុយទៅទិញសម្ភារៈទំនើបដែលខ្លួនបាន។ ក្នុងករណីនេះ **ក** និង **ខ** បានដឹងយ៉ាងច្បាស់ហើយថាការឆក់កាបូបជាអំពើដែលត្រូវច្បាប់ព្រហ្មទណ្ឌបានហាមឃាត់ និងត្រូវផ្តន្ទាទោសហើយបើទោះបីជាយ៉ាងនេះក្តីក៏ **ក** និង **ខ** នៅតែធ្វើសកម្មភាពនោះ។ ដោយឡែកកំហុសអចេតនា គឺចង់សំដៅទៅលើកំហុសដែលកើតឡើងពីការមិនអាចគ្រប់គ្រងឆន្ទៈរបស់ខ្លួនបានដែលបានសេចក្តីថាចារីមានគោលបំណងធ្វើសកម្មភាពរបស់ខ្លួនក៏ប៉ុន្តែចារីពុំមានឆន្ទៈ ឬពុំបានដឹងផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយស្របតាមក្រមព្រហ្មទណ្ឌបានចែងថា "បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការធ្វេសប្រហែស ការខ្ជីខ្ជា ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។[11]

ឧទាហរណ៍៖ លោក **ក** មានណាត់ជាមួយដៃគូរពាណិជ្ជកម្មលោក **ខ** នៅវេលាម៉ោង ៧:០០ ល្ងាច។ នៅម៉ោង៦:៣០នាទីល្ងាច កូនរបស់លោក **ក** មានអាការៈចុកពោះជាខ្លាំងដែលតម្រូវឲ្យមានការជូនទៅមន្ទីរពេទ្យជាបន្ទាន់។ លោក **ក** ក៏បានជូនកូនរបស់លោកទៅមន្ទីរពេទ្យដោយម៉ោង ៦:៥០ នាទីទើបទៅដល់មន្ទីពេទ្យ។ ដោយលោក **ក** ខ្លាចហួសម៉ោងណាត់ជួបលោក **ខ** នៅម៉ោង ៧:០០ លោក **ក** បានបើករថយន្តយ៉ាងលឿនសំដៅទៅកន្លែងណាត់។ នៅតាមផ្លូវធ្វើដំណើរខណៈពេលដែលកំពុងតែបើបរលឿនស្រាប់តែលោក **ក** មិនបានគោរពភ្លើងសញ្ញាចរាចរណ៍ក្រហមក៏បានជ្រុលចង្កូតទៅបុកលោក **គ** ដែលកំពុងតែជិះម៉ូតូហើយបណ្តាលឲ្យលោក **គ** ស្លាប់

[10] មាត្រា៤ កថាខណ្ឌ១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[11] មាត្រា៤ កថាខណ្ឌ២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

បាត់បង់ជីវិត។ នៅក្នុងឧទាហរណ៍នេះលោក **ក** មិនមានឆន្ទៈនៅក្នុងធ្វើឲ្យលោក **គ** ស្លាប់ទេ។ លោក **ក** មានគោលបំណងធ្វើសកម្មភាពដើម្បីទៅឲ្យទាន់ការណាត់របស់គាត់តាមរយៈការបំពានភ្លើងស្តុបក្រហម។

# ជំពូកទី២
# ការទទួលខុសត្រូវព្រហ្មទណ្ឌ
# របស់រូបវន្តបុគ្គល

# ជំពូកទី២

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

រូបវន្តបុគ្គលមានជាអាទិ៍ៈ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ជនបរទេស អណិកជន និងជនគ្មានសញ្ជាតិ។ ប៉ុន្តែជនទាំងនេះមានភារៈទទួលខុសត្រូវខាងបទព្រហ្មទណ្ឌបាន លុះត្រាតែជននោះមានអាយុគ្រប់កំរិតជានីត្យានុកូលដែលទទួលស្គាល់ច្បាប់ហើយបានផ្តល់សិទ្ធិពេញលេញជាប្រជាពលរដ្ឋ។ មានន័យថាជនដែលមានសមត្ថភាពគ្រប់គ្រាន់មានសតិប្រាជ្ញាមាំមួនមានវិចារណញ្ញាណត្រឹមត្រូវអាចដឹកនាំ ឬគ្រប់គ្រងនូវសកម្មភាពរបស់ខ្លួនបាននៅចំពោះមុខច្បាប់ដូចមានចែងក្នុងបញ្ញត្តិនៃច្បាប់។

## ២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

នីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញ នេះជាការចែងទុកជាមុនរបស់ច្បាប់ដោយកំណត់នូវកម្រិតអាយុក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ចាប់ពី ១៨ ឆ្នាំឡើង មានន័យថា ឆន្ទៈសង្គមរបស់មនុស្សភាគច្រើនតាមរយៈអ្នកតំណាងរាស្ត្របានបញ្ញត្តិច្បាប់ឡើងដោយទទួលស្គាល់ថា រូបវន្តបុគ្គលនៅពេលមានអាយុ ១៨ ឆ្នាំឡើងទៅ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ហើយមានសមត្ថភាពខាងផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌជាការប្រកាន់យក និងទទួលស្គាល់ជាលក្ខណៈគតិយុត្តពីរដ្ឋ ថាមនុស្សម្នាក់មានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

ជនទាំងឡាយណាមានសតិជានាល្អមានវិចារណញ្ញាណស្គាល់ខុសត្រូវជនទាំងឡាយនោះត្រូវមានភារៈទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានសមគំនិត និងចំពោះបំណងជាបទឧក្រិដ្ឋ ឬបំណងជាបទមជ្ឈិមខ្លះដែលខ្លួនបានធ្វើឲ្យប្រកបនឹងលក្ខខ័ណ្ឌដូចដែលច្បាប់បានបញ្ញត្តិទុករួចមកហើយ[12]។ ប៉ុន្តែការអនុវត្តទោសអាចអនុវត្តបានតែចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ លើកលែងតែមានកិច្ចព្រមព្រៀងដោយឡែកប៉ុណ្ណោះចំពោះអ្នកប្រព្រឹត្តបទល្មើសដែលជាជនបរទេស។ គោលការណ៍ការសំរេចធ្វើទោសនេះទៀតសោតនឹងត្រូវអនុវត្តបានតែចំពោះជនល្មើសជារូបវន្តបុគ្គលតែប៉ុណ្ណោះ។

### ២.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិជន គឺជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់។ សមត្ថភាព គឺសំដៅដល់សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ នីតិជន គឺជា បុគ្គលដែលមានលក្ខណៈ

[12] មាត្រា ៧៦ ក្រមព្រហ្មទណ្ឌសង្គមចាស់នៃព្រះរាជាណាចក្រកម្ពុជា

សម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនីតិជន គឺជាជនពេញវ័យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត។

### ២.១.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាគោលការណ៍នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រូវបានកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ។ នេះជាលក្ខខណ្ឌមួយដែលច្បាប់បានកំណត់យ៉ាងជាក់ច្បាស់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាគោលការណ៍ ប្រសិនបើបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គឺត្រូវ ទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញតាមច្បាប់កំណត់ ដែលនេះវាខុសពីអនីតិជនត្រូវទទួលខុសត្រូវត្រឹមតែពាក់កណ្តាលនៃទោសប៉ុណ្ណោះ។

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើស ទទួលខុសត្រូវនូវអំពើរបស់ខ្លួននៅចំពោះមុខច្បាប់ ព្រោះបើយើងគិតពីអាយុ និងការយល់ដឹងគឺអាចមានការយល់ ដឹងពេញលេញចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត គោលការណ៍នៃច្បាប់បានសន្មត់ទុកជាមុនថា ប្រជាពលរដ្ឋគ្រប់រូប គឺយល់ដឹងអំពីច្បាប់ ហើយការយល់ដឹងអំពីច្បាប់ សំដៅទៅលើការយល់ដឹងអំពីអំពើរបស់ខ្លួនថា ខុសច្បាប់ ឬមិនខុសច្បាប់។

ឧទាហរណ៍៖ អំពើលួច? យើងគ្រប់គ្នាប្រាកដជាដឹងហើយថា ការលួចទ្រព្យរបស់អ្នកដទៃ គឺជា អំពើខុសច្បាប់ទោះបីប្រជាពលរដ្ឋមិនអាចដឹងថាអំពើដែលប្រព្រឹត្តនោះមានចែងនៅក្នុងមាត្រាណា ច្បាប់ណា ក៏គាត់អាចយល់យ៉ាងច្បាស់ថា នេះជាអំពីអំពើខុសច្បាប់។

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសទទួលខុសត្រូវទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ មួយវិញទៀត ក៏មានមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ រួមមាន៖ អនីតិជនអាយុក្រោម ១៤ឆ្នាំ វិបល្លាសស្មារតី ការអនុញ្ញាត ដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ និង អានុភាពនៃកម្លាំង ឬការបង្ខំ។

### ២.១.២. ទោសដែលត្រូវអនុវត្តចំពោះនីតិជន

ទណ្ឌកម្មព្រហ្មទណ្ឌ គឺជាការដាក់ទោសទៅលើជនល្មើសដោយស្ថាប័នតុលាការចំពោះអំពើដែលជននោះ បានប្រព្រឹត្តខុសទៅនឹងច្បាប់។ ចំពោះការដាក់ទណ្ឌកម្មទៅលើជនល្មើស គឺមានគោលបំណងឱ្យជននោះ កែប្រែចិត្តគំនិតកុំឱ្យមានការប្រព្រឹត្តខុសម្តងទៀត ពោលគឺចង់ឱ្យជននោះក្លាយទៅជាពលរដ្ឋល្អ។

### ២.១.២.១. ប្រភេទនៃបទល្មើស

ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺបានបែងចែកបទល្មើសព្រហ្មទណ្ឌជា ៣ ប្រភេទទៅតាមទម្ងន់របស់បទល្មើស ដែលជននោះបានប្រព្រឹត្ត ថាតើជននោះបានប្រព្រឹត្តអំពើនោះស្ថិតនៅក្នុងបទល្មើសអ្វី។ ហើយបទល្មើសព្រហ្មទណ្ឌនោះទៀតសោតគឺត្រូវបានបែងចែកមានដូចជា បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ទៅតាមទម្ងន់នៃបទល្មើស។ បើតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាពិសេស គឺមានគោលការណ៍មួយដើម្បីកំណត់ថាបទល្មើសនោះជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ គេត្រូវពិនិត្យទៅលើអតិបរមានៃទោសដាក់ពន្ធនាគារដែលច្បាប់កំណត់សម្រាប់បទល្មើសនោះបានន័យថា គឺត្រូវពិនិត្យទៅលើអតិបរមានៃទោសដាក់គុកដែលមានចែងនៅក្នុងមាត្រានីមួយៗជាក់ស្តែង។

#### ក.បទល្មើសជាបទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាប្រភេទបទល្មើសដែលមានកម្រិតទោសអតិបរមាធ្ងន់ជាងគេ ជាទោសជាប់ពន្ធនាគារចាប់ពី៥ ឆ្នាំ រហូតដល់មួយជីវិត។ ក្នុងបទឧក្រិដ្ឋគេមានកំណត់គឺអតិបរមានៃទោសដាក់ពន្ធនាគារលើសពី៥ ឆ្នាំឡើងទៅ និងក្រោម ឬស្មើនិង ៣០ឆ្នាំ និងអស់មួយជីវិតគឺត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ[13]។

ឧទាហរណ៍៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, បទឃាតកម្ម, បទរំលោភសេពសន្ថវៈ, បទលួចដោយមានអំពើហិង្សា។ល។

ជាក់ស្តែងខ្ញុំសូមលើកយកនូវអំពី បទឃាតកម្ម ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ ១៥ឆ្នាំ[14]។ ដូច្នេះយើងអាចឃើញថា អតិបរមានៃទោសដាក់ពន្ធនាគារ កំណត់សម្រាប់បទឃាតកម្មនេះ គឺជាបទឧក្រិដ្ឋ។

#### ខ. បទល្មើសជាបទមជ្ឈិម

បទមជ្ឈិម គឺជាប្រភេទបទល្មើសដែលកម្រិតទោសអតិបរមាជាទោសជាប់ពន្ធនាគារចាប់ពី ៦ ថ្ងៃដល់ ៥ឆ្នាំ។ ឲក្នុងបទមជ្ឈិមគេបានកំណត់ អតិបរមានៃទោសដាក់ពន្ធនាគារចាប់ពី ៦ថ្ងៃដល់ ៥ឆ្នាំ[15]។

ឧទាហរណ៍៖ បទមនុស្សឃាតដោយ អចេតនា, លួច, បង្ករបួសស្នាម រឺ ហិង្សាដោយចេតនា, បទឆបោក, រំលោភលើសេចក្តីទុកចិត្ត។ល។

---

[13] មាត្រា ៤៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[14] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[15] មាត្រា ៤៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ជាក់ស្តែងខ្ញុំសូមលើកយកនូវអំពី បទមនុស្សឃាតដោយអចេតនាដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ឆ្នាំ ទៅ ៣ឆ្នាំ[16]។ ដូច្នេះយើងអាចឃើញថា អតិបរមានៃទោសដាក់ពន្ធនាគារកំណត់សម្រាប់បទមនុស្សឃាតដោយអចេតនាគឺ ៣ឆ្នាំនេះជា បទមជ្ឈិម ។

**គ. បទល្មើសជាបទលហុ**

បទលហុ គឺជាប្រភេទបទល្មើសដែកមានកម្រិតទោសអតិបរមាជាទោសជាប់ពន្ធនាគារតិចជាង ៦ថ្ងៃ ឬជាបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែជាប្រាក់ពិន័យសុទ្ធសាធដោយគ្មានទោសពន្ធនាគារ។ ក្នុងបទលហុ យើងអាចឃើញគោលការណ៍ពីរយ៉ាងដែលគោលការណ៍ទី១ ត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ គឺរយៈពេលក្រោម ឬស្មើនឹង៦ថ្ងៃ[17]។ ចំណែកឯគោលការណ៍ទី២ គឺត្រូវមើលទៅលើបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមត្រូវពិន័យជាប្រាក់ប៉ុណ្ណោះ។ ដូច្នេះបើយើងពិនិត្យឲ្យលម្អិតទៅឃើញថានៅក្នុងក្រមព្រហ្មទណ្ឌ បើទោះបីចំនួនប្រាក់ពិន័យនោះប៉ុន្មានដងក៏ដោយក៏ជាបទលហុដែរ។

ឧទាហរណ៍៖ ការបើកបរដោយមិនគោរពច្បាប់ចរាចរណ៍, ការជេរប្រមាថមន្ត្រីរាជការសាធារណៈ, ការបរិហាកេរ្តិ៍ ឬ ជេរប្រមាថសាធារណៈ, ការបង្ហាញនូវភាពស្រវឹងនៅទីសាធារណៈ។ល។ ជាក់ស្តែង បទបរិហាកេរ្តិ៍ជាសាធារណៈ ដែលមានចែងនៅក្នុងមាត្រា-៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងអំពី បទបរិហាកេរ្តិ៍ជាសាធារណៈគឺមានត្រឹមការពិន័យជាប្រាក់ប៉ុណ្ណោះ ដោយគ្មានការផ្តន្ទាទោសដាក់ពន្ធនាគារទេហេតុនេះវាគឺជា បទលហុ។[18]

កាលនៃបទឧក្រិដ្ឋ ១៥ឆ្នាំ បានកន្លងផុតទៅ ដោយគ្មានការចោទប្រកាន់ថ្មី ឬកិច្ចស៊ើបអង្កេត ជនដែលបាន ប្រព្រឹត្តបទល្មើសនោះ នឹងមិនត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាឡើយ។

ឧទាហរណ៍៖ លោក **ក** ប្រព្រឹត្ត បទទទួលផលចោរកម្ម ផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ៤ឆ្នាំ ក្នុងករណីនេះអាជ្ញាយុកាលនៃបទល្មើស គឺបទមជ្ឈិម រយៈពេល ៥ឆ្នាំ បើសិនផុតរយៈពេល ៥ឆ្នាំ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ ឬធ្វើបណ្តឹង អាជ្ញាមានដំណើរការឡើយ លើកលែងតែមានការចោទប្រកាន់ ឬកិច្ចស៊ើបអង្កេតថ្មី។

---

[16] មាត្រា ២០៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[17] មាត្រា ៤៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[18] មាត្រា ៣០៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

## ២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ការទទួលស្គាល់ថាកុមារដែលមានការសង្ស័យជាប់ចោទ ដែលគេស្គាល់ថាបានប្រព្រឹត្ត បទល្មើសទំនាស់នឹងច្បាប់ព្រហ្មទណ្ឌ គឺត្រូវបានចាត់រាល់វិធានការសមស្របដើម្បីជម្រុញការស្តារ កាយសម្បទា និងចិត្តសាស្ត្រឲ្យមានដូចដើមវិញ និង កុមាររងគ្រោះពីទម្រង់ណាមួយនៃការទុកចោលមិនយកចិត្តទុកដាក់ការកេងប្រវ័ញ្ច ឬការរំលោភ បំពាន ការធ្វើទារុណកម្ម ឬទម្រង់ណាមួយនៃការប្រព្រឹត្តទៅខ្លួនកុមារ ឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬដោយសារជម្លោះប្រដាប់អាវុធជាដើម" ។ ព្រហ្មទណ្ឌ គឺជានីតិវិធីទាំងឡាយណាដែលចែងមកសម្រាប់ដាក់ទោសរាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយពីនីតិវិធីព្រហ្មទណ្ឌ ។ ដូច្នេះហើយនៅពេលមានបទល្មើស មួយកើតឡើងត្រូវតែមានការទទួលខុសត្រូវព្រហ្មទណ្ឌ ។

### ២.២.១.លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើងដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលជាហេតុបណ្តាលឲ្យមានព្យសនកម្មដល់បុគ្គលដទៃ ជាគោលការណ៍តម្រូវឲ្យមានអ្នកទទួលខុសត្រូវចំពោះអំពើល្មើស តែច្បាប់ក៏បានលើកលែងដែរចំពោះបុគ្គលមួយចំនួនដូចជា អនីតិជនអាយុក្រោម១៤ ឆ្នាំ ជនវិបល្លាសស្មារតី ការការពារស្របច្បាប់ហើយការទទួលខុសត្រូវចំពោះអំពើល្មើសនោះទៀតសោត គេមិនអាចឲ្យជនដែលមិនយល់ដឹងអំពើរបស់ខ្លួនទៅទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ច្បាប់បានចែងយ៉ាងជាប់ច្បាប់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ[19]។ ផ្អែកតាមគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌអាយុគឺជាលក្ខខណ្ឌចំបងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវបានកំណត់យកអាយុនៅពេលដែលអនីតិជនប្រព្រឹត្តបទល្មើស[20]។ ការកំណត់អំពីកំរិតអាយុនៃការទទួលខុសត្រូវនេះ គឺជាការប្រកាន់យក និងទទួលស្គាល់ជាផ្លូវការពីសំណាក់រដ្ឋថា អនីតិជនម្នាក់នៅពេលដែលឈានដល់អាយុតាមការកំណត់នោះ ទើបមានលទ្ធភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ទាញចេញពីការកំរិតអាយុនេះ បង្កើតបានទៅជាមូលដ្ឋានផ្នែកគតិយុត្តមួយ សំរាប់កំណត់អំពីការ ទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន។ ជាមួយគ្នានេះដែរយើងសូមធ្វើការបែងចែកអនីតិជនជាពីរប្រភេទគឺ ៖

#### ២.២.១.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស

ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើសត្រូវស្ថិតនៅក្រោមការការពាររបស់ តុលាការ តុលាការចាត់តាំងបុគ្គលមួយរូបឲ្យទទួលភារៈធ្វើការតាមដានអនីតិជនរូបនោះ។ ប្រសិនជាអនីតិជនដែលមានអាយុចាប់

[19] មាត្រា ៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[20] មាត្រា ៩ កថាខណ្ឌ ១ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំទៅវិញនៅពេលដែលជននេះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហេតុដែលច្បាប់តម្រូវឲ្យជននេះមានការទទួលខុសត្រូវ ព្រោះយល់ឃើញថា អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ។ សមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេល ដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាច បញ្ជានូវរាល់អំពើទាំងនោះបាន។ ដោយការយល់ឃើញយ៉ាងដូច្នេះ អាស្រ័យហេតុថា នីតិករបានពិចារណាដោយផ្អែកទៅលើ ការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញា ស្មារតី និង ការសន្សំនូវរាល់បទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅកន្លងមករបស់អនីតិជននោះឯង។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណា យល់ដឹងបានគ្រប់គ្រាន់នូវបណ្តាការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាន នូវរាល់អំពើរបស់ខ្លួនថែមទៀតផង។ នៅក្នុងករណីនេះច្បាប់ទុកលទ្ធភាពឲ្យចៅក្រមធ្វើការពិនិត្យទៅលើជម្រើសនៃវិធានការដូចជា៖ ទីមួយចៅក្រមមិនអាចប្រកាសអំពីទោសព្រហ្មទណ្ឌទេបានន័យថា អត់អាចសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ចំពោះអនីតិជននោះទេតែចៅក្រមអាចប្រើប្រាស់នូវយន្តការផ្សេងដូចជា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភជាដើម។

ឧទាហរណ៍ ៖ ក្នុងករណីអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានធ្វើការបរិហាកេរ្តិ៍ និងការជេរប្រមាថជាសាធារណៈដល់ លោក **ក** បណ្តាលឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ នឹង កិត្តិយស ។ ករណីខាងលើចៅក្រមមិនអាចធ្វើការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនបានទេ ព្រោះថាករណីនេះ មិនមែនជាករណីធ្ងន់ធ្ងរដែលធ្វើអោយខូចខាតដល់ទ្រព្យសម្បត្តិ ឬ ដល់អាយុជីវិតទេ ដូចនេះចៅក្រមអាចជ្រើសរើសប្រើប្រាស់ត្រឹមតែ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ ដែលជាជម្រើសដ៏ត្រឹមត្រូវជាងគេ។

ទីពីរប្រសិនបើចៅក្រមបានពិនិត្យមើលឃើញយ៉ាងជាក់ច្បាប់ អំពីកាលៈទេសៈនៃបទល្មើសហើយ និងបុគ្គលិកលក្ខខណ្ឌរបស់ជនល្មើសដែលជាអនីតិជន នោះតម្រូវច្បាប់បើសិទ្ធិឲ្យតុលាការក៏អាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបានផងដែចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ ឆ្នាំដល់ក្រោម ១៨ឆ្នាំ។ បើសិនជាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអនីតិជន ដោយយោងតាមកាលៈទេសៈដោយយោងតាមបុគ្គលិកលក្ខណៈរបស់ជននោះ គឺតុលាការត្រូវអនុវត្តនូវមូលទោសដែលមានថេងតែអំពីមូលទោសមួយសម្រាប់តែអនីតិជននោះប៉ុណ្ណោះ។

ឧទាហរណ៍៖ អនីតិជនម្នាក់មានអាយុ ១៦ឆ្នាំបានប្រព្រឹត្តបទឧក្រិដ្ឋមួយដ៏សាហាវយង់ឃ្នងដូចជាគាត់ចាប់រំលោភសេពសន្ថវៈរួចហើយក៏សម្លាប់នារីរងគ្រោះនោះចោលថែមទៀត។ ដូចនេះករណីបែបហ្នឹង សាហាវ

ខ្លាំងណាស់គឺមិនអាចប្រើប្រាស់វិធានការតាមដានអប់ការពារ និងឧបត្ថម្ភអីបានទេអញ្ចឹងនៅក្នុងករណីនេះ ជម្រើសដ៏ត្រឹមត្រូវជាងគេប្រហែលជាត្រូវផ្ដន្ទាទោសព្រហ្មទណ្ឌហើយ។

### ២.២.១.២. កាលៈទេសៈនៃបទល្មើស

ដោយហេតុថា ច្បាប់ពុំបានកំណត់អំពីនិយមន័យ ឬ ផ្ដល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យកាលៈ ទេសៈនៃបទល្មើសឲ្យបានជាក់លាក់ ដូចនេះអាចឲ្យគេយល់បានថា កាលៈទេសៈនៃបទល្មើស គឺ សំដៅទៅលើកត្តារួមផ្សំនៃបទល្មើសនេះឯង។ មានន័យថា កត្តាទាំងនេះគឺស្ថិតនៅក្នុងធាតុសត្យានុម័តនៃបទល្មើសផ្ទាល់តែម្ដង ពោលគឺវាមានតួនាទីសំរាប់កំណត់បទល្មើស និងកំណត់អំពីព្រំដែនទណ្ឌកម្មផងដែរ។ ដើម្បីឲ្យងាយយល់កាន់តែច្បាស់ជាងនេះទៅទៀតនោះ គឺយើងអាចធ្វើការសិក្សាស្វែងយល់ និងពិចារណាតាមរយៈបទពិសោធន៍ជាក់ស្ដែងរបស់ចៅក្រមក្នុងការពិចារណានិងសំរេចអំពីទណ្ឌកម្មជាក់ស្ដែងទៅលើអនីតិជនដែលជាជនល្មើស តាមរយៈកត្តារួមផ្សំដូចខាងក្រោម ៖

-មធ្យោបាយប្រព្រឹត្តបទល្មើស

មធ្យោបាយប្រព្រឹត្តបទល្មើស សំដៅលើបណ្ដាវត្ថុ ឬសម្ភារៈ និងរួមបញ្ចូលទាំងឧបករណ៍ ប្រព្រឹត្តបទល្មើសផងដែរ ដែលអនីតិជននោះបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ។

-វិធីសាស្ត្រប្រព្រឹត្តបទល្មើស

វិធីសាស្ត្រប្រព្រឹត្តបទល្មើស សំដៅទៅលើបែបផែននៃវិធីក្នុងការប្រព្រឹត្តនូវអំពើល្មើសច្បាប់ មួយឡើង ។

-ពេលវេលាប្រព្រឹត្តបទល្មើស

អាចជាពេលមួយ ឬរយៈពេលមួយជាកំណត់ ដែលអំពើល្មើសច្បាប់ព្រហ្មទណ្ឌបានស្ដែងចេញមកខាងក្រៅ។ មានន័យថា នៅក្នុងច្បាប់ព្រហ្មទណ្ឌ ពេលវេលា ប្រព្រឹត្តបទល្មើស អាចជាសញ្ញាមួយសំរាប់កំណត់នូវបទល្មើសផ្ទាល់តែម្ដង ។

-ទីកន្លែងប្រព្រឹត្តបទល្មើស

ទីកន្លែងប្រព្រឹត្តបទល្មើស មានន័យថា ជារង្វង់ដែនដីមួយជាកំណត់ ដែលនៅទីនោះ បទល្មើសបានចាប់ផ្ដើម និងបញ្ចប់ ឬនៅទីនោះបច្ច័យនៃអំពើល្មើសច្បាប់បានកើតឡើង។ មានន័យថា ទីកន្លែងអាចជាចំណុចណាមួយ ឬជាតំបន់ដែនដីណាមួយជាកំណត់ ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិថា វាជាទីកន្លែងមួយដែលសំរាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ ។

-ទិដ្ឋភាពនានាជុំវិញបទល្មើស

ទិដ្ឋភាពនានាជុំវិញបទល្មើស ការសរុបនូវរាល់ករណីលំអិតនានាផ្នែកសត្យានុម័តជុំវិញ ការប្រព្រឹត្តបទល្មើសដែលមានឥទ្ធិពលទៅលើកំរិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស ដែលទិដ្ឋភាពជុំវិញនៃបទល្មើសទាំងនោះ ត្រូវបានច្បាប់បញ្ញត្តិ ជាសញ្ញានៃស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសផងដែរ ។

### ២.២.១.៣.បុគ្គលិកលក្ខណៈរបស់អនីតិជន

បុគ្គលិកលក្ខណៈរបស់អនីតិជនមានដូចជា អាយុ កម្រិតយល់ដឹង បញ្ញា និងអត្តចរិតរបស់អនីតិជននោះ។[21] ត្រង់ចំណុចនេះដែរ យើងឃើញថា នីតិករមានចេតនាចង្អុលបង្ហាញឲ្យឃើញយ៉ាងជាក់លាក់អំពី អត្ថន័យនៃពាក្យ បុគ្គលិកលក្ខណៈនេះផ្ទាល់តែម្តង គឺក្នុងគោលដៅដើម្បីបញ្ចៀសកុំឲ្យអ្នកសិក្សា ឬ អ្នកអនុវត្តច្បាប់មានការភណ្ឌច្រឡំទៅលើអត្ថន័យនៃពាក្យពេចន៍នេះ ហើយព្យាយាមធ្វើការបកស្រាយប្រាសចាកពីគោលគំនិតដើមរបស់ច្បាប់។ ទាញចេញពីខ្លឹមសារខាងលើអាចឲ្យគេយល់បានថា បុគ្គលិកលក្ខណៈរបស់អនីតិជន សំដៅទៅលើសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ របស់អនីតិជននោះផ្ទាល់តែម្តងចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះ តុលាការមុននឹងធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបាន ត្រូវពិចារណាអំពីការរីកចម្រើននៃរូបរាងកាយ របស់ អនីតិជន ប្រាជ្ញា ស្មារតី និងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់អនីតិជននោះជាមុនសិន។ ដើម្បីអាចវាយតម្លៃបានថា អនីតិជនអាចយល់ដឹង ឬមិនអាចយល់ដឹងបានគឺវាយតម្លៃបានតាមរយៈ ២បែប រួមមាន៖ របបវេជ្ជសាស្ត្រ និងរបបធម្មជាតិ។

-របបវេជ្ជសាស្ត

នៅក្នុងរបបនេះ គេត្រូវគិតពិចារណាទៅលើស្ថានភាពនៃជម្ងឺដែលនាំឲ្យជននោះមិនអាច យល់ដឹងបានដូចជាមនុស្សដែលស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំ។ ពោលគឺជាជនដែលមានជម្ងឺសរសៃប្រសាទជាប្រចាំ ឬខ្សោយសតិ សតិបញ្ញាពុំប្រក្រតី ឬជម្ងឺផ្សេងៗទៀតដែលបណ្តាល ឲ្យមានភាពរឹករវក្នុងសកម្មភាពនៃសរសៃប្រសាទនេះតែម្តង ។ ជម្ងឺសរសៃប្រសាទជាប្រចាំ (វិកលចរិត) អាចមានរូបភាពជាក់ស្តែងខុសៗគ្នា ដែលនាំមកនូវលទ្ធផលសភាពជម្ងឺជាប្រចាំ ឬយូរអង្វែង ។ សភាពរឹករវក្នុងសតិបញ្ញាជាបណ្តោះអាសន្ន ស្តែងឡើងភ្លាមៗក្នុងរយៈពេលខ្លី ធ្វើឲ្យមានការបាត់បង់នូវការយល់ដឹង ភ្លេចទាំងស្រុង ឬមួយផ្នែកនៃករណីដែលបានកើតឡើងក្នុងពេលវេលា ដែលជម្ងឺបានបញ្ចេញសកម្មភាព ។ ស្ថានភាពជម្ងឺផ្សេងៗ គឺជាប្រភេទជម្ងឺដែលពុំមែនកើតឡើងក្នុងប្រព័ន្ធសរសៃប្រសាទជាប្រចាំម្តងម្កាលឡើយ ប៉ុន្តែត្រូវបានចាត់ទុកថាជាស្ថានភាពជម្ងឺប្រហាក់ប្រហែល

[21] មាត្រា ៦៤ ចំណុច គ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទៅនឹងស្ថាន ភាពជម្ងឺសរសៃប្រសាទដូចជា ករណីប្រើប្រាស់អាភៀន ឬថ្នាំញៀន ជាដើម (ដល់ពេលដែលត្រូវជក់ ឬចាក់សារធាតុញៀន) ។

-របបតាមបែបធម្មជាតិ

ចំណែករបបនេះគឺគេពិចារណាទៅលើផ្នែកសេរីរាង្គ ដោយពិនិត្យទៅលើអាយុរបស់ជននោះ រួមទាំងចំណេះដឹងរបស់គាត់ផងដែរ។ ការពិចារណានេះ គឺផ្អែកទៅលើការរីកចំរើននៃផ្នែកសរីរាង្គ ដែលពាក់ព័ន្ធរួមមានបញ្ហាសរសៃប្រសាទ និងរាងកាយរបស់គាត់នោះឯង។ អាស្រ័យហេតុនេះ ទើបក្នុងច្បាប់បានសន្មតថា អាយុ ១៤ ឆ្នាំ គឺអាចមានសមត្ថភាពយល់ដឹងបានខ្លះៗហើយ ដោយសារតែស្ថានភាពនៃការរីកចម្រើនផ្នែកខាងរូបរាង្គកាយនៃមនុស្ស និងការទទួលនូវឥទ្ធិពលផ្នែកខាងធម្មជាតិ រួមមានដូចជា បញ្ហាដែលពាក់ព័ន្ធជាមួយនឹងអាកាសធាតុ សេដ្ឋកិច្ច និង សង្គមនេះឯង ។ ដូច្នេះហើយ ទើបនៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់ថា ប្រសិនបើជាអនីតិជនដែលមាន អាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ហើយបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ ចៅក្រមអាចប្រកាសផ្តន្ទាទោសទៅ លើអនីតិជននោះបាន ។ ការងារសហគមន៍ដែលយើងកំពុងតែសិក្សានេះ គឺគ្មានកម្រៃសម្រាប់ផ្តល់ឲ្យអនីតិជននោះទេ ដូច្នេះ គោលការណ៍ដែលច្បាប់បានកំណត់ត្រឹមអាយុ ១៦ ឆ្នាំនេះគឺជាការល្អប្រសើរបំផុតណាស់ទៅហើយ ។

### ២.២.២.ការអនុវត្តទោសចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

អនុសញ្ញាស្តីពីសិទ្ធិកុមារ និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួងចែងអំពីក្រម ដែលមានលក្ខណៈពេញលេញនៃសិទ្ធិកុមារដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន។ ការអនុវត្តទោស គឺជាដំណើរការនៃការអនុវត្តតាមនីតិវិធីដែលតុលាការបានធ្វើការផ្តន្ទាទោសចំពោះជនល្មើស ពោលគឺក្រោយពីតុលាការធ្វើការប្រកាសទណ្ឌកម្មចំពោះទណ្ឌិតណាម្នាក់រួចហើយ។ ចំពោះការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណង ឬការអនុវត្តទោសដូចទៅនឹងនីតិជនឡើយ។ ចំពោះរាល់ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឲ្យអនីតិជនក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[22]។ ហេតុនេះហើយត្រូវចែងឲ្យបានច្បាស់លាស់អំពីគោលបំណង ឬវត្ថុបំណងនៃការឃុំដែលផ្តោតលើការស្តារនីតិសម្បទាមិនមែនជាការដាក់ទណ្ឌកម្ម។ បើយោងតាមច្បាប់ស្តីពីយុត្តិធម៌ អនីតិជនដែលបានផ្តល់ឲ្យនូវអនីតិជនដែលបានផ្តន្ទាទោសត្រូវស្ថិតនៅជាលក្ខណៈជាជនដែលត្រូវទទួលនូវគោលការណ៍ស្តារនីតិសម្បទាតែប៉ុណ្ណោះ។

[22] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា៧៩ ឆ្នាំ២០១៦

ដូច្នេះហើយទើបធ្វើឲ្យមានការសម្រេចសេក្តីថាតុលាការគ្រប់លំដាប់ថ្នាក់អាចសម្រេចប្រគល់ទណ្ឌិតជាអនីតិជនដែលត្រូវបានផ្តន្ទាទោសទៅមណ្ឌលឃុំនីតិសម្បទារាជធានី ខេត្តណាមួយដែលសមស្របប្រសិនបើមានការសំណូមពរពីទណ្ឌិតជាអនីតិជន។ ជាមួយគ្នានេះផងដែរ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដដែលនេះ ក៏បានបញ្ញត្តិផ្តល់សិទ្ធដល់តុលាការក្នុងការប្រកាសទោសចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ក្នុងស្ថានភាពបែបនេះផងដែរដែល ក្នុងករណីមិនទាន់មានមណ្ឌលឃុំនីតិសម្បទា។ ដូច្នេះ ការអនុវត្តទោសចំពោះអនីតិជនក្នុងស្ថានភាពបច្ចុប្បន្ននឹងប្រព្រឹត្តទៅមានលក្ខណៈដូចខាងក្រោមៈ

**២.២.២.១. ទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ**

បទល្មើសព្រហ្មទណ្ឌទាំងឡាយដែលជនល្មើសបានប្រព្រឹត្តទោះដោយចេតនា ឬដោយអចេតនា ដោយផ្ទាល់ ឬដោយប្រយោលក្តីអំពើទាំងនោះ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមដូចគ្នា។ ក្រមព្រហ្មទណ្ឌ បញ្ញត្តិពីគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ របស់បុគ្គលម្នាក់ៗដោយត្រូវទទួលទោសព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ ពុំអាចបុគ្គលណាម្នាក់មកទទួលទោសជំនួសបានឡើយ កាលបើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ គ្រប់អាយុដែលច្បាប់បានកំណត់ឲ្យផ្តន្ទាទោសតាមទំហំនៃអំពើដែលបានប្រព្រឹត្ត។

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ប៉ុន្តែអនីតិជនដអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ក៏ត្រូវទទួលការផ្តន្ទាទោសផងដែរ ដោយតុលាការពិចារណាលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនដែលបានប្រព្រឹត្តបទល្មើស។

មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ បានបញ្ញត្តិ កាលតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅៈ[23]

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១(មួយ) ថ្ងៃ ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវ បន្ថយពាក់កណ្តាល។

[23] មាត្រា ១០៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារ មកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥(ប្រាំ)ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។ ក្រៅពីមូលទោស តុលាការក៏អាចប្រកាសទោសបន្ថែមលើអនីតជនដោយ ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ផលទុន ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ឧបភោគភណ្ឌចលនវត្ថុនៅក្នុងទីកន្លែងដែលប្រព្រឹត្តបទល្មើស និងហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ចំពោះអនីតិជនអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដែលតុលាការ ប្រកាសមូលទោស អាចនឹងទទួលការផ្តន្ទាទោសបន្ថែម ជាទោសការងារ សហគមន៍មានលក្ខណៈជាកាបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។ លើសពីនេះ បទប្បញ្ញត្តិស្តីពីការមិនរាងចោល នៃការប្រព្រឹត្តបទល្មើសរបស់អនីតិជនមិនត្រូវយកមកអនុវត្តលើអនីតិជនឡើង។[24]

**២.២.២.២. ប្រភេទនៃទោស**

ទោសព្រហ្មទណ្ឌត្រូវបានបែងចែកជា ៣ (បី) គឺៈ មូលទោស ទោសបន្ថែម និងទោសជំនួស។[25]

**ក. មូលទោស**

ទោសបញ្ញាត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះពុំទាន់មានចែង ឲ្យបានច្បាស់លាស់ នៅឡើយទេតែតាមគម្រោងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមានចែងសេចក្តីច្បាស់លាស់។ មូលទោសជាទោសដែលតុលាការបានសំរេច ពិគ្រោះអំពីទោសសកម្មដើម្បីផ្តន្ទាទោសលើជនល្មើសណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងបញ្ញត្តិច្បាប់ដែលបានដៅទុកជាធរមានមកនោះ ទោសនេះជាប្រភេទនៃទោសដែលតុលាការមានសិទ្ធិសំរេចដាច់ដោយឡែកតែឯងក៏បានដោយមិនបាច់បញ្ចូលអនុទោស ឬទោសបន្ថែមមកក៏បាន បញ្ចូល មកក៏បាន។

មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយការពិន័យត្រូវគិតជាប្រាក់រៀល។ ចំពោះប្រាក់ពិន័យដែលទទួលបានត្រូវបង់ចូលជាថវិការដ្ឋ ពោលគឺប្រាក់ពិន័យនេះមិនមែនជាប្រាក់សំណងរដ្ឋប្បវេណី ដែលភាគីបង្កបង់សងជម្ងឺចិត្តទៅជនរងគ្រោះទេ។ ទោសដាក់ពន្ធនាគារ គឺជាទោសដែលលុបបំបាត់

[24] មាត្រា ១៦៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[25] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ទាំងអស់ នូវសិទ្ធិសេរីភាពជាមូលដ្ឋាន ឬយើងហៅជា សាមញ្ញថាជាប់ពន្ធនាគារ ឬជាប់គុក។ ទោសដាក់ពន្ធនាគារនេះ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[26]។ កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។ ចំណែកឯទោសពិន័យជាប្រាក់ គឺតម្រូវឱ្យទណ្ឌិតបង់ប្រាក់តាមច្បាប់កំណត់ ហើយប្រាក់ពិន័យត្រូវទុក ចូលជាថវិការដ្ឋដែលត្រូវទុកនៅរតនាគារជាតិ ដោយ[27]។ កាលបើបទល្មើស ត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។

ឧទាហរណ៍៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១ឆ្នាំ ទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០រៀល ទៅ ៦.០០០.០០០រៀល។ [28]ការពិន័យបែបនេះហៅថាមូលទោស។

**ខ. ទោសបន្ថែម**

ទោសបន្ថែម គឺជាទោសបន្ទាប់បន្សំដែលចៅក្រមសម្រេចបន្ថែមក្នុង មូលទោសហើយ ទាល់តែតុលាការសម្រេចថាបុគ្គលរូបណា មានមូលទោសហើយទើបតុលាការអាចសម្រេចដាក់ទោសបន្ថែមពីលើមូលទោសនោះបាន។ លើសពីនេះទៅទៀតទោសសបន្ថែមបង្កើតឡើងក្នុងគោលបំណង ដើម្បីឲ្យការដាក់ទណ្ឌកម្មមានភាពសមស្របទៅនឹងអំពើល្មើសច្បាប់ដែលបុគ្គលរូបនោះបានប្រព្រឹត្ត ឬធានាដល់ការអនុវត្តគោលការឯកត្តកម្មនៃទោស។

ទោសបន្ថែម នឹងអាចប្រកាសទៅបានលុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះ បទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុ ដែលត្រូវបានចោទប្រកាន់។ ហើយទោសបន្ថែមអាចប្រកាសក៏បានមិនប្រកាសបាន ប៉ុន្តែប្រសិនបើមានច្បាប់ចែងយ៉ាងជាក់លាក់នោះទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[29] ប្រភេទទោសបន្ថែមនេះរួមមាន៖[30]

-ការដកសិទ្ធិខ្លះជាពលរដ្ឋ៖[31]

---

[26] មាត្រា ៤៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[27] មាត្រា ៥២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[28] មាត្រា ២១៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[29] មាត្រា ៥៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[30] មាត្រា ៥៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[31] មាត្រា ៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ជាទូទៅ ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបតែងតែមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ហើយចំពោះការប្រើប្រាស់សិទ្ធិ និងករណីយកិច្ចសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គល គឺមិនត្រូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃទៀតឡើយ ចំពោះការប្រើសិទ្ធិនេះដែរគឺត្រូវបានប្រព្រឹត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់។

សិទ្ធិពលរដ្ឋដែលអាចដកបានដូចជា សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញជាអាជ្ញាកណ្តាល ឬជាអាណត្តិរបស់តុលាការ សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ សិទ្ធិធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ ទោសនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។

- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ៖ [32]

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈមិនអនុវត្តទៅលើការបំពេញអាណត្តិ ដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ។ ការហាមឃាត់នេះមិនអាចអនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ។ ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥(ប្រាំ) ឆ្នាំយ៉ាងច្រើនហើយតុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវបានហាមឃាត់។

ឧទាហរណ៍៖ លោក **ក** ជាគ្រូពេទ្យហើយបានប្រព្រឹត្តខុសទៅនឹងវិជ្ជាជីវៈរបស់ខ្លួនដែលបណ្តាល ឲ្យអ្នកជំងឺរងគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរ។ ដូចនេះ តុលាការអាចប្រកាសទោសបន្ថែមដោយហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈដែលបានប្រព្រឹត្តក្នុងពេលប្រកបវិជ្ជាជីវៈព្យួរអាជ្ញាប័ណ្ណរបស់គាត់ជាដើម។[33]

-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ៖[34]

ចំពោះបទល្មើសខ្លះមិនថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬក៏បទលហុទេ ទោសបន្ថែមគឺត្រូវហាមឃាត់មិនឲ្យធ្វើការបើកបរយានយន្តគ្រប់ប្រភេទ ដែលការហាមឃាត់មិនឲ្យបើកបរយានយន្តមិនត្រូវលើសពី៥(ប្រាំ) ឆ្នាំទេ។

-ការព្យួរលិខិតបើកបរ៖[35]

ក្នុងករណីដែលអ្នកបើកបរយានយន្តគ្រប់ប្រភេទបានប្រព្រឹត្តបទល្មើស តុលាការអាចសម្រេចសេចក្តីក្នុងការព្យួរលិខិតបើកបររបស់ជនល្មើសបាន នៅពេលតុលាការសម្រាចរឿងក្តីជាស្ថាពររួចហើយសេចក្តីសម្រេចរបស់តុលាការខាងលើត្រូវជំនួសដោយសេចក្តីសម្រេចរបស់សាលក្រម ឬសាលដីកា។ ទោសព្យួរលិខិតបើកបរ

[32] មាត្រា ៥៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[33] មាត្រា ៥៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[34] មាត្រា ៥៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[35] មាត្រា ៥៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

មិនត្រូវលើសពី៥(ប្រាំ) ឆ្នាំទេ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

-ការហាមឃាត់ចំពោះការស្នាក់នៅ៖[36]

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិតចំពោះការមានមុខនៅកន្លែងខ្លះលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា។ ទោសនេះមិនអាចលើសពី ១០ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង៥ឆ្នាំ ចំពោះបទមជ្ឈិម។ តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ចិរវេលានៃការហាមឃាត់។ ការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដានដែលទណ្ឌិតត្រូវតែ៖ ចូលបង្ហាញខ្លួនតាមដីកាកោះ របស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង និងចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការ កំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។ ទោសនេះមិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម ។ តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និង កំណត់ចិរវេលានៃការហាមឃាត់។

-ការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដានទណ្ឌិតត្រូវតែ ៖

១-ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាល ដែលតុលាការបានចាត់តាំង ។

២-ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ ។

-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា៖[37]

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាមិនត្រូវលើសពី ៥ (ប្រាំ)ឆ្នាំ។ ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការលិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេក្នុងរយៈពេលដែលកំពុងទទួលទោសនោះ ។

[36] មាត្រា ៥៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[37] មាត្រា ៦០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស៖[38]

ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេសការហាមឃាត់ដល់ ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះនាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញ ដោយពេញច្បាប់នៅពេល បញ្ចប់ទោសដាក់ពន្ធនាគារ ។

-ការរឹកអូសឧបករណ៍សម្ភារៈ ឬវត្ថុដែកប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ៖[39]

១-ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការ ប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែល បទល្មើសបានប្រព្រឹត្ត ។ ប៉ុន្តែការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ៖[40]

ការចាត់ចែងទ្រព្យសម្បត្តិរឹបអូសកាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជា កម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែក ដែលចែងអំពីការប្រគល់ផ្សេងពីនេះ ។ រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យ សម្បត្តិរដ្ឋ ។

- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ៖[41]

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន

[38] មាត្រា ៦១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[39] មាត្រា ៦២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[40] មាត្រា ៦៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[41] មាត្រា ៦៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ៖[42]

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការ ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ ៖

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែល ត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ៖[43]

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើ សកម្មភាពនៅក្នុង គ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ។ ទោសបិទគ្រឹះស្ថាននេះអាច ជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ៖[44]

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណៈជន ឬដែលប្រើប្រាស់ដោយសាធារណៈជន ឬ ដែលត្រូវប្រើប្រាស់ដោយសាធារណៈជនអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ៖[45]

ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុល បង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ទេ ។ ការបិទផ្សាយអាចធ្វើ

[42] មាត្រា ៦៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[43] មាត្រា ៦៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[44] មាត្រា ៦៧ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[45] មាត្រា ៦៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ទាំងស្រុង ឬតាមសម្រង់ ឬ តាមនិទ្ទេសធម្មតា ។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្តី ប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី ។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយ ដោយអ្នកបំបាត់ចោល លាក់បំបាំង ឬអ្នកហែកចោលសេចក្តី ប្រកាសនេះ ។

-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ៖[46]

ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មាន សរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មាន មិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ ។

-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ សោតទស្សន៍ ៖[47]

ទោសផ្សាយជាសាធារណៈនូវសេចក្តីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយ តុលាការ ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ទេ ។ ការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬ តាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត ។

**គ. ទោសជំនួស**

ទោសជំនួស គឺអាចត្រូវបានតុលាការយកមកប្រើប្រាស់ជំនួសទោសចំពោះការប្រព្រឹត្តបទល្មើសណា មួយ។ ទោសជំនួស សំដៅលើទោសការងារសហគមន៍ ឬការស្តីបន្ទោសដែលជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសទោសការងារសហគមន៍ ឬការស្តីបន្ទោស ពុំអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។ តុលាការពុំអាចប្រកាសទោសជំនួសទាំងពីរនេះ ត្រួតគ្នាបានឡើយ។ មូលហេតុដែលសម្រេចអំពីទោសជំនួស គឺដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ គេអាចពិនិត្យទៅលើស្ថានភាព កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីអនុវត្តទោសដែលជាមូលដ្ឋាន ដោយយកទោសជំនួសមកអនុវត្តវិញ។ ទោសជំនួស ត្រូវបានបែងចែកជា ២(ពីរ) គឺ ទោសការងារសហគមន៍ និងទោសស្តីបន្ទោស។

- ទោសការងារសហគមន៍

ទោសការងារសហគមន៍ គឺជាទោសថ្មីស្រឡាងសម្រាប់កម្ពុជាយើង ហើយយើងនឹងធ្វើការពន្យល់នូវចំណុចនីមួយៗឲ្យបានក្បោះក្បាយដូចតទៅ៖

[46] មាត្រា ៦៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[47] មាត្រា ៧០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ទោសការងារសហគមន៍ គឺជាទោសជំនួសមួយប្រភេទដែលតម្រូវឲ្យទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី៣០(សាមសិប) ម៉ោង ទៅ២០០(ពីររយ)ម៉ោង ដោយគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀតដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[48] ហើយតុលាការអាចប្រកាសទោសការងារសហគមន៍បាន ហើយកាលណាជនជាប់ចោទទួសទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង៣(បី) ឆ្នាំ។[49] ដូច្នេះទោសការងារសហគមន៍គឺសំដៅដល់កាតួកិច្ចមួយដែលត្រូវបំពេញនៅការងារមួយដែលគ្មានកម្រៃ និងប្រយោជន៍សាធារណៈបានន័យថាជាប្រយោជន៍របស់រដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ឬរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយការងារសហគមន៍នោះទៀតសោតអាចប្រែប្រួលរយៈពេល ម៉ោងធ្វើការចាប់ពី៣០(សាមសិប) ម៉ោង ទៅ២០០(ពីររយ)ម៉ោង។ និយមន័យនៃការងារសហគមន៍នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង៣(បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍។[50] ការងារសហគមន៍គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី៣០ (សាមសិប) ម៉ោងទៅ ២០០(ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍របស់រដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់នីតិបុគ្គលនៃនីតិសាធារណៈដទៃទៀត ឬរបស់សមាគម ឬរបស់អង្គការមិនមែនរដ្ឋាភិបាល។

ឧទាហរណ៍៖ ជាក់ស្តែងតុលាការមិនប្រកាសពីមូលទោសទេ ប៉ុន្តែគាត់អាចប្រកាសអំពីការងារសហគមន៍ប្រសិនបើជននោះគាត់មានវត្តមាននៅពេលសវនាការ ហើយគាត់យល់ព្រមទទួលយកការងារសហគមន៍គឺតុលាការអាចប្រកាសការងារសហគមន៍ដូចជា ធ្វើការងាររយៈពេល៥០ ម៉ោងដើម្បីជាប្រយោជន៍សាធារណៈមួយក៏ប៉ុន្តែ ការងារសហគមន៍នេះព្រះរាជអាជ្ញាមិនមែនចេះតែឲ្យគាត់ធ្វើពីមួយថ្ងៃទៅមួយថ្ងៃដោយឥតឈប់នោះទេ គឺត្រូវធ្វើនៅពេលម៉ោងណាមួយដែលទុកពេលវេលាផ្សេងទៀតឲ្យគាត់ទៅធ្វើការរកស៊ីដើម្បីឲ្យគាត់បានចិញ្ចឹមជីវិតខ្លួនគាត់ និងចិញ្ចឹមជីវិតគ្រួសារគាត់ផង។ ដូច្នេះគឺចំណេញទាំងអស់គ្នាដោយរដ្ឋមិនបាត់បង់សមាជិករបស់ខ្លួន ថែមពីលើទៀតនោះគឺកាត់បន្ថយការចំណាយរបស់រដ្ឋដូចជាចំណាយទៅលើការចិញ្ចឹម ការបីបាច់ ការថែក្សា មិនត្រឹមតែប៉ុណ្ណឹងគ្រួសារគាត់ក៏ត្រូវតែជួបនូវការលំបាកកាន់តែខ្លាំងឡើយ។

- ទោសស្តីបន្ទោស

[48] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១១ លេខរៀង៤៧

[49] មាត្រា ៣២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[50] មាត្រា ៧២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ការស្តីបន្ទោសនេះ ក៏ជាទោសថ្មីស្រឡាងសម្រាប់កម្ពុជាយើងហើយដូចនឹងទោសការងារសហគមន៍ដែរ។ ចំពោះទោសស្តីបន្ទោស គឺជាប្រភេទទោសមួយដែលក្នុងនោះគឺជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាលហើយចៅក្រមគាត់មិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់អ្វីនោះទេ ប៉ុន្តែចៅក្រមគាត់អាចប្រកាសទោសនេះបានព្រោះ ទោសស្តីបន្ទោសគឺជាការព្រមានការប្រដៅអំពីទោសកំហុសឆ្គងដែលគាត់បានប្រព្រឹត្តហើយជាការព្រមានថាកុំឲ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត។ ម៉្យាងវិញទៀតទោសស្តីបន្ទោសគឺភាពច្រើនប្រើចំពោះកុមារ ឬអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើយទៅដល់ក្រោម ១៨ឆ្នាំ។ ការស្តីបន្ទោសគឺតុលាការអាចប្រកាសស្តីបន្ទោសកាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬ ស្មើនឹង៣ (បី)ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោសប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ៖ [51]

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។

### ២.២.២.៣.ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន

សម្រាប់អនីតិជនអាយុចាប់ពី១៤ ឆ្នាំ ឡើងទៅ តុលាការអាច ប្រកាសទណ្ឌកម្មបាន។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់គឺ ទោសនេះតែម្តង។ ការកំណត់អាយុ១៤ ឆ្នាំសម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្មស្របតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឲ្យមានការ ឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន។ ចំពោះអនីតិជនមានអាយុចាប់ពី១៤ ឆ្នាំ ដល់ ១៨ឆ្នាំក្នុងល្ខខណ្ឌកំណត់ដោយច្បាប់ និងក្នុងចិរវេលាក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ អនីតិជនក៏អាចទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ដូចនីតិជនផងដែរ។ ក៏ប៉ុន្តែអ្វីដែលខុសគ្នានោះនៅត្រង់ថា របបនៃទោសដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន គឺមិនដូចគ្នាទៅនឹងរបបនៃទោសដែលអនុវត្តចំពោះនីតិជនឡើយ ពោលគឺអនីតិជនមាននូវរបបគតិយុត្តពិសេសមួយដាច់ដោយឡែកពីនីតិជន។[52] ជាងនេះទៅទៀតដោយហេតុថាអនីតិជនមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតនៅឡើយ កាលបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ តុលាការក៏អាចសម្រេចឲ្យអនីតិជនទទួលបាននូវស្ថានសម្រាលទោសផងដែរ។

[51] មាត្រា ៧៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[52] មាត្រា ១០៦ដល់ ១៦៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

**២.២.២.៤. ស្ថានសម្រាលទោសចំពោះអនីតិជន**

កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថាន សម្រាលទោស។[53] ស្ថានសម្រាលទោសក៏អាចត្រូវបានផ្តល់ឲ្យជនជាប់ចោទបានដែរ ទោះបីជាជននោះត្រូវបានប្រកាសថាស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ។ ដូច្នេះ ស្ថានសម្រាលទោសនេះ អាចយកទៅអនុវត្តលើគ្រប់បទល្មើសបានទាំងអស់ [54]។ ស្ថានសម្រាលទោស គឺជាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ដែលញ៉ាំងឲ្យតុលាការសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោសមានន័យថា ស្ថានសម្រាលទោស គឺជាការគិតគូររបស់តុលាការដោយផ្អែកទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះតម្រូវ[55]។ ហើយការពិចារណានេះអាចតាមរយៈ សាវតា ចំណេះដឹង អាកប្បកិរិយា ស្ថានភាពគ្រួសារ ឬមួយក៏ការសារភាពទទួលស្គាល់នូវទោសកំហុសដោយខ្លួនឯង និងគ្មានការបង្ខិតបង្ខំណាមួយឡើយ។ ដូចនេះ ក្នុងករណីដែលតុលាការបានសម្រេចឲ្យអនីតិជន បានទទួលនូវស្ថានសម្រាលទោស នោះអប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចខាងក្រោម ៖

១. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ៦ (ប្រាំមួយ) ខែ ។

៣. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥(ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ៣ (បី) ខែ ។

**២.២.២.៥.ការអនុវត្តទោសដាក់ពន្ធនាគារ**

ពន្ធនាគារ សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាន់ឃុំតាមលិខិតឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការរួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែជង[56]។ ការដាក់ពន្ធនាគារអនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌត្រូវតែជាវិធានការចុងក្រោយបង្អស់ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ[57]។ គោលបំណងចម្បងក្នុងការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារ គឺដើម្បីធ្វើការអប់រំ

---

[53] មាត្រា ៩៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[54] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៣៤៥

[55] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ២៣៦

[56] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៤ ចំណុច ១ ឆ្នាំ២០១១

[57] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៣៧ ៩(ខ)

កែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តានីតិសម្បទាដល់ទណ្ឌិតដែលជាអនីតិជននោះតែប៉ុណ្ណោះ។ ដូច្នេះ ការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារនឹងប្រព្រឹត្តទៅតាមរយៈពីរចំណុចសំខាន់ៗដែលមានលក្ខណៈដូចខាងក្រោមៈ

-ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ

ការឃុំឃាំងក្នុងពន្ធនាគារ គឺជានីតិវិធីមួយដែលធ្វើការឃុំឃាំងអនីតិជនដែលជាជនជាប់ឃុំនៅក្នុងបន្ទប់ឃុំឃាំងហើយការណ៍ដែលឃុំឃាំងនេះទៀតសោធន៍ ក៏ត្រូវបានបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំនីមួយៗនោះផងដែរ។ ជនជាប់ឃុំសំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារតាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ[58]។ ចំពោះជនជាប់ឃុំជាអនីតិជនត្រូវបានដាក់បំបែកពីជនជាប់ឃុំជានីតិជន។ ជនជាប់ឃុំដែលជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជនត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត[59]។ ក្រៅពីនេះជនជាប់ឃុំឃាំងជាស្ត្រីត្រូវបានដាក់បំបែកពីជនជាប់ឃុំជាបុរស និងចំពោះជនជាប់ឃុំដទៃទៀតផងដែរ។ ការបែងចែកការឃុំខ្លួនអនីតិជននៅពន្ធនាគារទៅតាមប្រភេទដែលមានលក្ខណៈខុសប្លែកគ្នាពីការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដោយការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបានបែងចែកជាបីផ្នែកដូចជា[60]៖

១. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន

២.ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជន ដើម្បីទទួលយកកម្មវិធីស្តារនីតិសម្បទា

៣.ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហារណកម្ម។

-ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ

ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ ជាភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធនាគារចំណុះឲ្យក្រសួងមហាផ្ទៃ និងពន្ធនាគាររាជធានី ខេត្ត។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ព្រះរាជអាជ្ញាប្រធានសភាស៊ើបសួរ និង ចៅក្រមស៊ើបសួរត្រូវបានធ្វើអធិការកិច្ចពន្ធនាគារស្របទៅតាមរមនីតិវិធីព្រហ្មទណ្ឌ។ យន្តការបង្កាថ្នាក់ជាតិក៏ត្រូវបានអនុញ្ញាត្តិឲ្យចូលទស្សនៈកិច្ចពន្ធនាគារផងដែរ ក្នុងគោលបំណងត្រួតពិនិត្យលើលក្ខខណ្ឌនៃការឃុំខ្លួន

[58] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៤ ចំណុច ៣ ឆ្នាំ២០១១

[59] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ២៦ ឆ្នាំ២០១១

[60] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧៧ ឆ្នាំ២០១៦

និងការប្រព្រឹត្តចំពោះជនជាប់ឃុំ និង ផ្តល់អនុសាសន៍បន្ថែមដើម្បីកែលម្អការប្រព្រឹត្តទៅរបស់ពន្ធនាគារអោយមានភាពល្អប្រសើរ [61]។

រាល់ការអនុវត្តទោសដាក់ពន្ធនាគារ គឺត្រូវធ្វើឡើងស្របទៅតាមច្បាប់ស្តីពីពន្ធនាគារ និង ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ ក្រសួងមហាផ្ទៃ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង ពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង មានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឲ្យក្នុងការគ្រប់គ្រងពន្ធនាគារ[62]។ ក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មមុខងារឲ្យរដ្ឋបាលរាជធានី-ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគាររាជធានី-ខេត្ត ហើយពន្ធនាគារនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈ អភិបាលរាជធានី-ខេត្ត[63]។ ពន្ធនាគារ ត្រូវគ្រប់គ្រងដោយប្រធានពន្ធនាគាមួយរូប ហើយមានអនុ ប្រធានពន្ធនាគារ យ៉ាងតិចមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ពន្ធនាគារនីមួយៗ ត្រូវមានអ្នកផ្តល់ការថែទាំសុខភាពមួយរូប និងមន្ត្រីអនុរក្សពន្ធនាគារជាច្រើនរូប ផ្សេងទៀតដែលមានតួនាទី និង ភារកិច្ចថែរក្សា ព្រមទាំងជម្រុញឲ្យការងារពន្ធនាគារដំណើរការ ទៅបានប្រកបដោយប្រសិទ្ធភាពខ្ពស់ [64]។

ប្រធានពន្ធនាគារ ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងពន្ធនាគារទៅតាមនីតិវិធី និង បទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឲ្យបានត្រឹមត្រូវ[65]។ មន្ត្រីពន្ធនាគារ អាចធ្វើការឆែកឆេរជនជាប់ឃុំ និងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ ប្រសិនបើជនជាប់ឃុំដែលបដិសេធមិនឲ្យមន្ត្រីពន្ធនាគារឆែកឆេរត្រូវ ចាត់ទុកថាជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ [66]។

### ២.២.២.៦ .ការអនុវត្តទោសពិន័យចំពោះអនីតិជន

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទដែលស្ថិតក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងៗទៀតដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស ពោលគឺសំដៅទៅលើ ទោសមួយប្រភេទដែលមានគោលដៅធ្វើឲ្យជនល្មើសនោះមានការរាងចាលតែម្តង[67]។ ដូច្នេះ ក្នុងករណីអនីតិជនម្នាក់បានប្រព្រឹត្តបទ

---

[61] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៥៤ ឆ្នាំ២០១១

[62] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៥-៦ ឆ្នាំ២០១១

[63] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៩ ឆ្នាំ២០១១

[64] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ

[65] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៤៣ ឆ្នាំ២០១១

[66] ច្បាប់ស្តីពីពន្ធនាគារ មាត្រា ៤៤ ឆ្នាំ២០១១

[67] ទោសព្រហ្មទណ្ឌ, លោក កៅ សីហា

ល្មើស ចៅក្រមអាចប្រកាសឲ្យអនីតិជននោះបង់សំណងចូលថវិការរដ្ឋផង និងសម្រេចឲ្យបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះថែមទៀត។ ដើម្បីអាចធានាបាន នូវការបង់ប្រាក់ពិន័យ វិធានការជាទូទៅដែលត្រូវលើកយកមកអនុវត្តចំពោះទណ្ឌិតដែលជាអនីតិជននោះ គឺការដាស់តឿនអោយបង់ប្រាក់ពិន័យធ្វើឡើងដោយអាជ្ញាធរតុលាការ ។

-ការដាស់តឿនឲ្យបង់ប្រាក់ពិន័យ[68]

ជាទូទៅ ប្រសិនបើដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់ទេ នោះអង្គភាពរតនាគារ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ក្រោយពីបានទទួលដំណឹងនេះហើយ ព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់មួយសម្រាប់ទុកដល់ ទណ្ឌិតដែលជាអនីតិជននោះដើម្បីអោយបង់ប្រាក់ពិន័យ។ រីឯចំពោះរយៈពេលដែលព្រះរាជអាជ្ញា បានកំណត់នោះមិនអាចតិចជាង ១០ ថ្ងៃឡើយ។ មិនតែប៉ុណ្ណោះ ការជូនដំណឹងនេះទៀតសោតន៍ ចាំបាច់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល កងរាជអាវុធហត្ថផងដែរ។ លើសពីនេះទៅទៀត ការឲ្យដំណឹងនេះត្រូវតែមានការធ្វើជាកំណត់ហេតុដែល ត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតម្រាមដៃ ក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថលេខា ។ សូមបញ្ជាក់ផងដែរថា ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿន ឲ្យទណ្ឌិតដែលជាអនីតិជននោះ បង់ប្រាក់ពិន័យបែបនេះក៏ដោយ។ ដោយឡែក ក្នុងករណីដែលអនីតិជននោះនៅតែមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយ ចំពោះអនីតិជននោះបានឡើយ ។

-ការរួចខ្លួនពីការបង្ខំដល់រូបរាងកាយ

ការបង្ខំដល់រូបកាយ ត្រូវអនុវត្តទៅលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយដែលជននោះមិនបានបង់នូវប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាអាទិ៍។ ដូច្នេះ ដើម្បីធានាឲ្យបាននូវការបង់ប្រាក់ពិន័យ មានវិធានការពីរ យ៉ាងដែលអាចលើកយកមកអនុវត្តបាន គឺ ការរឹបអូស និងការបង្ខំដល់រូបកាយ។ រីឯវិធានការរឹបអូសទ្រព្យសម្បត្តិវិញ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិដូចដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ គេសង្កេតឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌមិនបាន កំណត់អំពីការបង្ខំដល់រូបកាយ អាចធ្វើទៅបានលុះត្រាតែទណ្ឌិតមានចេតនាគេចវេស មិនព្រមបង់ប្រាក់ពិន័យឡើយ។ ក្នុងន័យនេះ អាចនាំឲ្យមានការបកស្រាយបានថា ការបង្ខំដល់រូបកាយដើម្បី ទាមទារប្រាក់ពិន័យអាចប្រព្រឹត្តទៅបាន បើទោះបីជាទណ្ឌិតលើកសំអាងថា ខ្លួនមិនមានលទ្ធភាព គ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យក៏ដោយ[69]។ ក៏

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥២៥ ឆ្នាំ ២០០៧

[69] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៥១

ប៉ុន្តែ ការបកស្រាយបែបនេះនឹងធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំង ដល់សិទ្ធិរបស់បុគ្គលដែលមានជីវភាពក្រីក្រ ហើយដែលពិតជាមិនមានលទ្ធភាពបង់ប្រាក់ពិន័យប្រាកដមែន និងនៅទីបំផុតបែរជាទទួលរងនូវការចាប់ដាក់ពន្ធនាគារដោយសារតែមូលហេតុនេះ។ ហេតុដូច្នេះ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់តម្រូវឲ្យមាន ការគេចវេសដោយចេតនាក្នុងការបង់ប្រាក់ពិន័យ ដើម្បីអាចបង្ខំដល់រូបកាយបានក៏ដោយ ក៏គួរគប្បីកំណត់ជា យុត្តិសាស្ត្រនូវលក្ខខណ្ឌនេះ ដើម្បីធានាឲ្យមាននូវការគោរពសិទ្ធិ និងភាពជាមូលដ្ឋាន របស់បុគ្គលដែរ[70]។

ដោយឡែកក្នុងករណីនេះ ច្បាប់ក៏បានបញ្ញត្តិយ៉ាងជាក់លាក់ផងដែរថា ការបង្ខំដល់រូបកាយ គឺមិនអាចអនុវត្តទៅលើទណ្ឌិតជាអនីតិជនបានឡើយ នៅពេលដែលបានប្រព្រឹត្តបទល្មើស។ មានន័យថាគោលការណ៍ដែលច្បាប់បានកំណត់បែបនេះ ព្រោះអាស្រ័យដោយហេតុថា អនីតិជនជាជនដែល ស្ថិតនៅក្នុងវ័យមួយកំពុងមានការរីកលូតលាស់នៅឡើយ ប្រសិនបើអនុញ្ញាតឲ្យមានការអនុវត្តការបង្ខំដល់រូបកាយនោះ និងបង្កឲ្យមានការប៉ះពាល់ដល់ការវិវត្តរបស់ពួកគេជាមិនខាន។ លើសពីនេះទៅទៀតក៏អាចបណ្ដាលឲ្យពួកគេមាននូវស្លាកស្នាមអាក្រក់ជិតដាមជាប់ក្នុងអារម្មណ៍ និងជះឥទ្ធិពលដល់ការរស់នៅព្រមទាំងការវិវត្តរបស់ពួកគេទៅថ្ងៃអនាគតផងដែរ។

[70] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៤៨

# ជំពូកទី៣

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

# របស់រូបវន្តបុគ្គល

# ជំពូកទី៣
# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

## ៣.១. មូលហេតុវិបល្លាសស្មារតី

នៅក្នុងសង្គមមានបណ្តាលអំពើរបស់មនុស្សដែលពិនិត្យលើរូបរាងដូចជាបទល្មើស ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញាត្តិ ប៉ុន្តែអំពើនោះបានបំពេញតាមលក្ខខណ្ឌមួយចំនួនដែលច្បាប់ព្រហ្មទណ្ឌបានចាត់ទុកថាជាអំពើមានប្រយោជន៍ដល់សង្គមជាពិសេសស្របច្បាប់ ហើយជនដែលបានប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងករណីដែលច្បាប់បានចែងយ៉ាងច្បាស់លាស់។

### ៣.១.១. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយមូលហេតុវិបល្លាសស្មារតី

ការកើតមានវិបល្លាសស្មារតី គឺសំដៅទៅលើវិបត្តិដែលធ្វើឲ្យមានការប៉ះពាល់ដល់សកម្មភាពនៃសរសៃប្រសាទដែលធ្វើឲ្យមនុស្សបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ឬសំដៅដល់ការប្រែប្រួលស្មារតីដែលនាំឲ្យបាត់បង់ដឹងខុសត្រូវ ឬមានការអន់ថយនូវការយល់ដឹងខុសត្រូវ។ ប្រព័ន្ធសរសៃប្រសាទមានសកម្មភាពមិនប្រក្រតីដែលអាចធ្វើឲ្យចារីបាត់បង់នូវលទ្ធភាពយល់ដឹងអំពីសកម្មភាពរបស់ខ្លួន ហើយវិបល្លាសស្មារតីអាចមានប្រភពមកពីការគ្រោះថ្នាក់ ឬ អាចមកពីជំងឺណាមួយជាដើម។ ដោយយោងនូវមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយហេតុមានវិបល្លាសស្មារតីមានដូចខាងក្រោម៖

#### ៣.១.១.១.មានវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវ

ការមានវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវ ក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មីបានបញ្ញត្តិថា "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ"។[71] ដូច្នេះជនណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅពេលអវត្តមាននៃការយល់ដឹងខុសត្រូវទាំងស្រុង ឬកើតមកអំពីវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់នូវការយល់ដឹងខុស ត្រូវទាំងស្រុងនោះច្បាប់បានបញ្ញត្តិឲ្យគាត់រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

#### ៣.១.១.២. មានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

ការមានវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ បើបុគ្គលម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឲ្យបាត់បង់ការដឹងខុសត្រូវរបស់ខ្លួននោះ ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលបន្ថយ

[71] មាត្រា ៣១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

នូវការដឹងខុសត្រូវរបស់ខ្លួនជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។[72] បន្ថែមលើនេះចៅក្រមត្រូវតែធ្វើការពិចារណាថ្លឹងថ្លែងអំពីកម្រិតយល់ដឹង របស់ចារីឲ្យបានច្បាស់លាស់ មុននឹងវិនិច្ឆ័យអំពីភាពធ្ងន់ឬស្រាលនៃទោសដែលសម្រាប់ដាក់ចំពោះចារីនៃអំពើនោះ។ សរុបមកវិញកាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។

### ៣.១.១.៣.មានវិបល្លាសស្មារតីដោយប្រើសារជាតិដែលច្បាប់បានហាមឃាត់

ការមានវិបល្លាសស្មារតីដោយប្រើសារជាតិដែលច្បាប់បានហាមឃាត់ លើសពីនេះទៅទៀតច្បាប់ព្រហ្មទណ្ឌពុំបានលើកលែងនូវការទទួលខុសត្រូវចំពោះបុគ្គលណាដែលកើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬដោយសារជាតិដែលច្បាប់បានហាមឃាត់នោះទេ។ មានន័យថាទោះបីជាមានវិបល្លាសស្មារតីកើត ឡើង ក្នុងពេលប្រព្រឹត្តបទល្មើសដោយការវិបល្លាសនោះកើតដោយសារការសេពគ្រឿង ស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់នោះចារីនៃបទល្មើស មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ និយាយសង្ខេបបើទោះបីជាអ្នកប្រើប្រាស់សារធាតុទាំងនេះគ្មានចេតនាទៅប្រព្រឹត្តបទល្មើសក៏ដោយ ក៏ច្បាប់នៅតែឲ្យគាត់ទទួលខុសត្រូវព្រហ្មទណ្ឌដដែល ពោលគឺគាត់មានចេតនាចំពោះអំពើតែអចេតនាចំពោះបច្ច័យ។

## ៣.២. មូលហេតុស្តីពីអំពើយុត្តិកម្ម

អំពើយុត្តិកម្ម សំដៅដល់ការប្រព្រឹត្តអំពើដែលត្រូវផ្តន្ទាទោសតាមច្បាប់ ប៉ុន្តែបែរជាត្រូវចាត់ថាត្រឹមត្រូវទៅវិញ នៅពេលដែលការប្រព្រឹត្តអំពើនោះបង្ហាញពីការបំពេញកាតព្វកិច្ច ឬអនុវត្តសិទ្ធិ បានសេចក្តីថាអំពើនោះបានកើតឡើងដោយសារតែផលប្រយោជន៍ស្របច្បាប់។ អំពើនោះបានកើតឡើងដោយសារតែផលប្រយោជន៍ស្របច្បាប់ហើយផលប្រយោជន៍នេះមានសារៈសំខាន់ជាងការចាត់ទុកអំពើនោះជាបទល្មើស។[73]

មូលហេតុស្តីពីអំពើយុត្តិកម្ម គឺជាមូលហេតុដែលគេចាត់ទុកថាចេញមកពីក្រៅបុគ្គលនៃចារី ហើយដែលធ្វើឲ្យចារីបានរួចផុតពីការទទួលខុសនឹងនាំឲ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក៏រួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាទៅនឹងចារីផងដែរ។ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ មិនបានប្រើពាក្យយុត្តិកម្មនៃបទល្មើសឲ្យចំទេ ដោយគ្រាន់តែចាត់ទុកករណីទាំងបីខាងលើនេះជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចជាវិបល្លាសស្មារតី កម្លាំងនិងការបង្ខំដែរ។ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាថ្មីបញ្ជាក់ថា អំពើអាចហៅថាជាអំពើយុត្តិ

---

[72] មាត្រា ៣១ កថាខណ្ឌ ២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[73] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ២៤៨

កម្ម មាន៣ចំណុចគឺ ទី១ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរស្របច្បាប់ ទី២ ការការពារស្របច្បាប់ និងទី៣ ស្ថានភាពចាំបាច់។

### ៣.២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

តាមរយៈការសិក្សាយើងឃើញមានសញ្ញាណមួយដែលអ្នកនីតិបញ្ញត្តិបានបង្កើតជាយុត្តិកម្មនូវអំពើដែលតាមធម្មតាជាបទល្មើស ប៉ុន្តែត្រូវបានចាត់ទុកថាមិនមែនជាបទល្មើសដោយច្បាប់ជាអ្នកបង្គាប់បញ្ជា ឬដោយសារតែការបង្គាប់បញ្ជារបស់អាជ្ញាធរ។ ដែលនៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់ថាជា "ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ" ខ្ញុំសូមធ្វើការបែងចែកការសិក្សានេះជាពីរ គឺទី១ ការអនុញ្ញាតដោយច្បាប់ និងទី២ ការអនុញ្ញាតដោយអាជ្ញាធរ។

១.ការអនុញ្ញាតដោយច្បាប់ ដែលឯកសារមួយចំនួនហៅថា "សេចក្តីបង្គាប់របស់ច្បាប់" គឺមានកំណត់យ៉ាងច្បាស់ក្នុងក្រមព្រហ្មទណ្ឌថ្មីដែលបានកំណត់ថា "បុគ្គលណាដែលប្រព្រឹត្ត អំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតដោយច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ [74]នេះបានន័យថាមិនបានប្រព្រឹត្តបទល្មើសតែវាជាអំពើស្របច្បាប់ ព្រោះច្បាប់បានអនុញ្ញាត។ ការអនុញ្ញាតដោយច្បាប់ គឺជាការផ្តល់នូវសិទ្ធិក្នុងការធ្វើអ្វីមួយដែលតាមរយៈការកំណត់ដោយច្បាប់នេះ បុគ្គលដែលអនុញ្ញាតដោយច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

២.ការអនុញ្ញាតដោយអាជ្ញាធរ ចំពោះករណីទាក់ទងនឹងការបញ្ជារបស់អាជ្ញាធរ បើតាមក្រមព្រហ្មទណ្ឌកម្ពុជាថ្មី បានកំណត់ថា "បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់លាក់។ [75]ការអនុញ្ញាតនេះជាលក្ខខណ្ឌមួយដែលជាគោលការណ៍គឺ មិនប្រព្រឹត្តបទល្មើសទេ។ តើអ្វី ទៅជាអាជ្ញាធរស្របច្បាប់? យោងតាមសទ្ទានុក្រមពាក្យច្បាប់របស់ទីស្តីការគណរដ្ឋមន្ត្រី បានផ្តល់និយមន័យរបស់ពាក្យ "អាជ្ញាធរ" ថាជាអ្នកទ្រទ្រង់នូវអាជ្ញា អ្នកកាន់អំណាចតាមសិទ្ធិដែលបានទទួលពេញលេញ។ អាជ្ញាធរទីនេះសំដៅលើអាជ្ញាធរស្របច្បាប់ពោល "អាជ្ញាធរស្របច្បាប់" សំដៅលើអាជ្ញាធរដែលទទួលសិទ្ធិ និងអំណាចតាមការកំណត់ផ្តល់របស់ច្បាប់ អាជ្ញាធរស្របច្បាប់ក្នុងន័យនេះគឺផ្អែកតាមយុត្តិសាស្ត្រប្រទេសបារាំងដែលបំពេញបន្ថែម ហើយដែលតុលាការកម្ពុជាដែលនឹងបំពេញបន្ថែម គឺមានន័យថាជាអាជ្ញាធរសាធារណៈដែលជាតំណាងឲ្យអំណាចសាធារណៈហើយជាអាជ្ញាធរមានសមត្ថកិច្ច។

---

[74] មាត្រា ៣២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[75] មាត្រា ៣២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

### ៣.២.២. ការការពារស្របច្បាប់

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ចំពោះការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើស ត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យសម្បត្តិ ប្រឈមមុខនឹងការល្លោនពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា នឹងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ ដែលប្រើប្រាស់និងទម្ងន់នៃការឈ្លានពាន។[76]

### ៣.២.៣. ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។
- គ្មានវិសមាមាត្ររវាងមធ្យោយបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។"

### ៣.២.៤. អានុភាពនៃកម្លាំងបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្ស តែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចឃើញជាមុនបាន និងមិនអាចជៀសវាងបាន។ មានន័យថា រាល់បុគ្គលដែលបានត្រូវទទួលការប្រើប្រាស់ កម្លាំង ឬការបង្ខំពីសំណាក់ជនណាម្នាក់ឲ្យប្រព្រឹត្តអំពើដែលផ្ទុយនិងច្បាប់ បុគ្គលនោះពុំបានទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ បុគ្គលដែលបាន ប្រើប្រាស់កម្លាំង និងបង្ខំជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសនោះទេ ទើបជាជនដែលនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់។ ការបង្ខំមានពីរប្រភេទគឺ ការបង្ខំលើរូបកាយ និងការបង្ខំលើផ្លូវចិត្ត៖

១.កម្លាំងបង្ខំលើរូបកាយ សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារី ដែលជាហេតុធ្វើឲ្យចារីត្រូវតែប្រព្រឹត្តអំពើដោយខ្លួន ពុំអាចឃាត់ឃាំងអំពើនោះបាន។ កម្លាំងបង្ខំលើរូបកាយអាចជា កម្លាំងបង្ខំមកពីខាងក្រៅ (កម្លាំងមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជន) និង កម្លាំងបង្ខំមកពីស្ថានភាព

[76] មាត្រា ៣៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ខាងក្នុងរបស់ចារី (ការភ្លាំងភ្លាត់មកពីសុខភាពខាងក្នុងរបស់ចារីក្នុងពេលកើតហេតុ ដែលហេតុនោះមិនបានកើតឡើងដោយចេតនា)។

២.កម្លាំងបង្ខំលើផ្លូវចិត្ត សំដៅកម្លាំងដែលបង្ខំឆន្ទៈរបស់ចារីឲ្យប្រព្រឹត្តបទល្មើស ហើយព្រឹត្តិការណ៍ក្រៅឆន្ទៈនោះ ចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ពោលជាការគាបសង្កត់ឲ្យចារីប្រព្រឹត្តបទល្មើសមិនអាចជៀសបាន។[77]

[77] នីតិព្រហ្មទណ្ឌទូទៅ,សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ២៤៣ ដល់ ២៤៥

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ" ដែរមានការទទួលខុសត្រូវជារូបវ័ន្តបុគ្គលហើយរូបវ័ន្តបុគ្គលបានចែកចេញជាពីរ នីតិជន និង អនីតិជន រួចមកយើងសង្កេតឃើញថានៅពេលជនណាបានប្រព្រឹត្តបទល្មើស គឺមិនអាចជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ពោលគឺមានការទទួលខុសត្រូវលើទង្វើដែលខ្លួនបានប្រព្រឹត្តនៅចំពោះមុខច្បាប់ដូចគ្នា ប៉ុន្តែថាអនីតិជនគឺស្ថិតនៅក្នុងដំណាក់កាលកំពុងវិវឌ្ឍន៍ ដែលពួកគេស្ថិតនៅក្នុងវ័យកំពុងលូតលាស់ផ្នែកចិត្តគំនិត និងការគិតពិចារណារបស់ពួកគេ។

ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការដាក់ទណ្ឌកម្មចំពោះជនល្មើស វាជាគឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការរៀបចំសណ្តាប់ធ្នាប់សង្គមឲ្យមានរបៀបរៀបរយផងដែរ ពីព្រោះថានៅពេលដែលមានការដាក់ទណ្ឌកម្មគឺធ្វើឲ្យទណ្ឌិតមានភាពរាងចាលចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ ដូចនេះដើម្បីឲ្យសង្គមមានសន្តិភាពកាត់បន្ថយបទល្មើសដែលកើតមានឡើងក្នុងសង្គម ក៏ដូចជាឲ្យប្រពលរដ្ឋបានយល់ដឹងកាន់តែច្បាស់ និងមានភាពយុត្តិធម៌ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះដែរ តុលាការប្រកាសឲ្យទណ្ឌិតទទួលខុសត្រូវព្រហ្មទណ្ឌ គឺក្នុងគោលបំណងចង់ឲ្យបុគ្គលនោះចេះកែកំហុស និងធ្វើខ្លួនឲ្យទៅជាពលរដ្ឋល្អរស់នៅក្នុងសង្គមដូចធម្មតាវិញ មិនមានគោលបំណងចង់ឲ្យបុគ្គលទាំងនោះមានភាពអាម៉ាសអាប់អោនកិត្តិយសឡើង។ រីឯការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះលក្ខខណ្ឌនៃការមិនទទួលខុសត្រូវគឺមាន ៣ មូលហេតុសំខាន់ ដែលទី១ ចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ប្រសិនបើចារីនោះបានប្រព្រឹត្តបទល្មើសនៅពេលដែលខ្លួនស្ថិតក្នុងភាពវិបល្លាសស្មារតីដែលសំដៅលើវិបត្តិ ដែលធ្វើឲ្យមានភាពរឹករវដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស។ ទី២បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬនៃការបង្ខំដែលបុគ្គលនោះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ ដែលកម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ ទី៣ ប្រសិនបើចារីនោះប្រព្រឹត្តបទល្មើសដោយសារមូលហេតុស្តីពីអំពើយុត្តិកម្ម គឺជាមូលហេតុដែលគេចាត់ទុកថាចេញមកពីក្រៅបុគ្គលនៃចារី ហើយធ្វើឲ្យចារីបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នឹងនាំឲ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិតក៏រួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នានឹងចារីផងដែរ។

ដូច្នេះបើទោះបីជាចៅក្រម និងព្រះរាជអាជ្ញា គាត់មានអំណាចដូចមានចែងនៅក្នុងច្បាប់ក៏ដោយក្នុងនោះក៏តម្រូវឲ្យគាត់មានឯករាជ្យភាពជាចាំបាច់ គឺត្រូវមានភាពឯករាជ្យភាពដែលកើតឡើងចេញពីឆន្ទៈដោយខ្លួនឯង និង ការធានាឯករាជ្យពីមជ្ឈដ្ឋានខាងក្រៅ។ ក្នុងការអនុវត្តការងារវិជ្ជាជីវៈមិនត្រូវប្រព្រឹត្តអំពើពុករលួយ និង ជៀសវាងឲ្យបាននូវអំពើអគតិធម៌ទាំង៤ គឺលម្អៀងព្រោះ ស្រលាញ់ ស្អប់ ខ្លាច ល្ងង់។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាទៅលើប្រធានបទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និង ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ នាងខ្ញុំសុំអនុញ្ញាតិផ្តល់ជូននូវសំណូមពរមួយចំនួនដូចខាងក្រោម៖

សុំសំណូមពរដល់ថ្នាក ក្រសួងយុត្តិធម៌មេត្តាចាត់វិធានការបន្ថែម ដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ បន្តការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌទណ្ឌនេះ ដល់ប្រជាពលរដ្ឋឲ្យបានដឹងកាន់តែច្បាស់ពីក្រមមួយនេះ និងច្បាប់ដោយឡែកផ្សេងទៀត។ និងសុំសំណូមពរដល់ស្ថាប័នតុលាការមេត្តាស៊ើបសួរ និងរកភ័ស្តុតាងឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើការជំនុំជម្រះដើម្បីជាភាពយុត្តិធម៌ដល់មហាជន ក៏ដូចជាពលរដ្ឋទូទាំងប្រទេស។

សូមសំណូមពរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មេត្តាជួយចាត់វិធានការឬជួយសម្រួលដល់អាជ្ញាធរ ដែលមានសមត្ថកិច្ចក្នុងការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ។

សូមសំណូមពរដល់អាជ្ញាធរសាធារណៈ មេត្តាពិនិត្យអំពីស្ថានភាពនៃបទល្មើសនិងស្រាវជ្រាវឱ្យបានច្បាស់លាស់សិន មុននិងធ្វើកំណត់ហេតុដាក់ជូនព្រះរាជអាជ្ញា ដើម្បីពង្រឹង និងបង្ហាញឱ្យកាន់តែច្បាស់លាស់ពីការអនុវត្តន៏យ៉ាងមុតមាំរបស់ប្រទេសកម្ពុជា ទៅតាមដំណើរឆ្ពោះទៅកាន់នីតិរដ្ឋ។

សំណូមពរដល់គ្រឹះស្ថានឧត្តមសិក្សា និងគ្រប់សាកលវិទ្យាល័យទាំងអស់គួរតែ បញ្ចូលកម្មវិធីសិក្សាអំពីមុខវិជ្ជាច្បាប់ ជាពិសេសក្រមព្រហ្មទណ្ឌនេះដល់និស្សិត ដែលមកសិក្សានៅសាលារបស់របស់ខ្លួន។

សូមណូមពរដល់អ្នកដែលមានជំនាញផ្នែកច្បាប់ដូចជា លោកបណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូខាងផ្នែកច្បាប់ដែលសរសេរសៀវភៅច្បាប់ឱ្យមានការបកស្រាយក្បោះក្បាយ ងាយយល់ ងាយចាប់បាន ដើម្បីឱ្យអ្នកដែលមិនចេះពាក្យបច្ចេកទេសផ្នែកច្បាប់ ចេះត្រឹមតែអានអក្សរក៏អាចយល់បានកាន់តែច្បាស់អំពីច្បាប់។

សំណូមពរដល់បណ្តាប្រជាពលរដ្ឋទាំងអស់ មេត្តាព្យាយាមសិក្សាស្វែងយល់ អំពីច្បាប់ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និងត្រូវតែទទួលយក និងជួយគ្នាអនុវត្តទាំងអស់គ្នាដើម្បីធានាឲ្យច្បាប់មួយមាននិរន្តរភាព និងជួយឲ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋយ៉ាងពិតប្រាកដ។

សំណូមពរជូនចំពោះប្រជាពលរដ្ឋ ដែលគាត់បានស្វែង ពីច្បាប់ខ្លះៗ ធ្វើការចែករំលែកដល់ប្រជា-ពលរដ្ឋដែលគាត់មិនបានដឹងសោះបានស្វែងយល់ពីច្បាប់មួយចំនួន យល់សម្រាប់ការរស់នៅក្នុងប្រទេសឱ្យមានភាពសមមាត្រនឹងគ្នា។ ដោយផ្អែកលើទស្សនៈមួយថា "អ្នកចេះបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកដែលមិនចេះសោះ" ទស្សនៈគឺជាវប្បធម៌ចែករំលែកមួយយ៉ាងល្អសម្រាប់ការស្វែងយល់ទាំងអស់គ្នា

# ឯកសារយោង

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ និង ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៤

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រក/ម/១១០៩/០២ ចុះនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩

៣. ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៧

៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ និង ច្បាប់ស្តីពីវិសោធនកម្ម ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

៥. ច្បាប់ស្តីពីពន្ធនាគារប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

៦. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦

៧. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

## II. លិខិតបទដ្ឋានគតិយុត្តជាតិ

១. អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមត្រូវបានអនុម័តឆ្នាំ ១៩៨៩

## III. សៀវភៅតែងនិពន្ធ

១. សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ២០១១

២. ទោសព្រហ្មទណ្ឌ  សាស្ត្រាចារ្យ កៅ សីហា បោះពុម្ពឆ្នាំ ២០១៣

៣. នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ ហ៊ី សោភា បោះពុម្ពឆ្នាំ

៤. នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត បោះពុម្ពឆ្នាំ ២០១២

# ឧបសម្ព័ន

# ឧបសម្ព័ន

១. ច្បាប់ស្ដីពីពន្ធនាគារប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

២. កំណត់ហេតុសួរចម្លើយ

៣. កំណត់ហេតុទទួលយកវត្ថុចាប់យក

៤. កំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

៥. ដីការបង្គាប់ឲ្យឃុំខ្លួន

៦. ដីការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

៧. ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យសើុបសួរ

៨. ដីការបង្គាប់ឲ្យចាប់ខ្លួន

# ច្បាប់

# ស្តីពី

# ពន្ធនាគារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៤/២២

# ព្រះរាជក្រម

នស/រកម/១២១១/០២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សម្មាទិដ្ឋិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីពន្ធនាគារ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងកំណត់អំពីការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលដៅដូចតទៅ :

- អប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និង ទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី

- គ្រប់គ្រងជនជាប់ឃុំឲ្យជានាបានសន្តិសុខ សុវត្ថិភាព សុខភាព និង មនុស្សធម៌ ស្របតាមគោលការណ៍អន្តរជាតិ និង វិធានសហប្រជាជាតិ សម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើពន្ធនាគារទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែពន្ធនាគារយោធា ឬកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ ឬមណ្ឌលឃុំខ្លួនដទៃទៀត ដែលកំណត់ដោយច្បាប់ផ្សេង ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

**ពន្ធនាគារ** សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង ។

**អនីតិជន** សំដៅដល់បុគ្គលទាំងឡាយណា ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ឡើង ដល់ក្រោម ១៨ ឆ្នាំ ។

**ជនជាប់ឃុំ** សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ ។

**មន្ត្រីពន្ធនាគារ** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មន្ត្រីពេទ្យពន្ធនាគារ** សំដៅដល់មន្ត្រីដែលត្រូវបានតែងតាំងឲ្យផ្តល់សេវាថែទាំសុខភាពជនជាប់ឃុំក្នុងពន្ធនាគារ និងត្រូវបានទទួលស្គាល់ ឬបានចុះបញ្ជីជាគ្រូពេទ្យ ឬមន្ត្រីពេទ្យនៅក្រសួងសុខាភិបាល ។

**អ្នកសួរសុខទុក្ខ** សំដៅដល់ជនដែលត្រូវបានអនុញ្ញាតឲ្យចូលក្នុងពន្ធនាគារ ដើម្បីសួរសុខទុក្ខ ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**អ្នកសួរសុខទុក្ខផ្លូវការ** សំដៅដល់មន្ត្រីសាធារណៈ ឬតំណាងបុគ្គលមកពីអង្គការនានា ដែលទទួលបានការអនុញ្ញាតឲ្យទៅធ្វើទស្សនកិច្ចឃ្លាំមើលតាមពន្ធនាគារនានា ឬផ្តល់ជំនួយដល់ជនជាប់ឃុំ ។

**យន្តការបង្ការថ្នាក់ជាតិ** សំដៅដល់យន្តការឯករាជ្យមួយ ស្របតាមពិធីសារបន្ថែមស្តីពីការបង្ការអំពើទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងមហាផ្ទៃជាស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៦.-**

អគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឲ្យក្រសួងមហាផ្ទៃ ក្នុងការគ្រប់គ្រងពន្ធនាគារ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

មន្ត្រីពន្ធនាគារត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែក ដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.-**

មន្ត្រីពន្ធនាគារមានឯកសណ្ឋាន សញ្ញាសក្តិ គ្រឿងបំពាក់ ឧបករណ៍ និងសម្ភារៈការពារសមស្រប ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៩.-**

ក្រសួងមហាផ្ទៃ ត្រូវធ្វើប្រតិភូកម្មមុខងារឲ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគាររាជធានី ខេត្ត ។

ពន្ធនាគាររាជធានី ខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈអភិបាលរាជធានី ខេត្ត ។

## ជំពូកទី ៣
## ហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ

**មាត្រា ១០.-**

ហេដ្ឋារចនាសម្ព័ន្ធរបស់ពន្ធនាគារត្រូវគោរពតាមបទដ្ឋានអប្បបរមា សម្រាប់ការសាងសង់ពន្ធនាគារ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១១.-**

អគារ និងបន្ទប់ឃុំឃាំង ត្រូវមានពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ មានបន្ទប់អនាម័យ មានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់ ។

**មាត្រា ១២.-**

ពន្ធនាគារត្រូវមានប៉ុស្តិ៍សុខភាព មានបន្ទប់សម្រាកព្យាបាលជនជាប់ឃុំ និងត្រូវមានមន្ត្រីពេទ្យពន្ធនាគារបម្រើការងារជាប្រចាំ ។

សេវាសុខាភិបាលពន្ធនាគារត្រូវស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេស... 

**មាត្រា ១៣.-**

ពន្ធនាគារត្រូវមានកន្លែងសម្រាប់គោរពជំនឿសាសនា មានបណ្ណាល័យ និងអគារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ១៤.-**

ពន្ធនាគារត្រូវរៀបចំឲ្យមានកន្លែងហាត់ប្រាណសម្រាប់ជនជាប់ឃុំ ។

**មាត្រា ១៥.-**

ពន្ធនាគារត្រូវមានកន្លែងធ្វើការ និងផ្ទះមុខងារ សម្រាប់មន្ត្រីពន្ធនាគារក្នុងអំឡុងពេលនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ១៦.-**

ការបង្កើត ការដាក់ឈ្មោះ ការកំណត់ទីតាំង ការកំណត់ចំនួនជនជាប់ឃុំ ការផ្លាស់ប្តូរឈ្មោះ ការផ្លាស់ប្តូរទីតាំង និងការរំលាយពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ការឃុំឃាំង

**មាត្រា ១៧.-**

ការទទួល ឬការឃុំខ្លួនជនណាម្នាក់នៅក្នុងពន្ធនាគារបាន លុះត្រាតែមានលិខិតឃុំខ្លួនដែលចេញពីអាជ្ញាធរតុលាការ ។

**មាត្រា ១៨.-**

មុនពេលទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលបានទទួលការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឲ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ ។

**មាត្រា ១៩.-**

មន្ត្រីពេទ្យពន្ធនាគារត្រូវពិនិត្យសុខភាពជនជាប់ឃុំ មុននឹងទទួលយកចូលក្នុងពន្ធនាគារ ដោយត្រូវកត់ត្រាបញ្ចូលក្នុងកំណត់ហេតុនូវព័ត៌មានអំពីស្ថានភាពសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ២០.-**

បន្ទាប់ពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ មន្ត្រីពន្ធនាគារត្រូវណែនាំដល់ជនជាប់ឃុំអំពីច្បាប់ បទបញ្ជាផ្ទៃក្នុងពន្ធនាគារ សិទ្ធិស្វែងរកអ្នកតំណាងផ្លូវច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ អំពីការជាប់ពន្ធនាគារ និងទីតាំងនៃពន្ធនាគារ ព្រមទាំងសិទ្ធិ និងករណីយកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងករណីជនជាប់ឃុំជាជនបរទេស ប្រធានពន្ធនាគារត្រូវអនុញ្ញាតឲ្យជនជាប់ឃុំជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។ ប្រសិនបើជនជាប់ឃុំមិនមានលទ្ធភាពជូនដំណឹងបាន ប្រធានពន្ធនាគារត្រូវធ្វើកិច្ចការនេះ ។

ក្រោយពីបានទទួលការណែនាំនេះ ជនជាប់ឃុំត្រូវផ្តិតម្រាមដៃ និង បិទ ឬស្កេនរូបថតបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីរក្សាទុកជាអចិន្ត្រៃយ៍ក្នុងសំណុំឯកសារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២១.-**

ពន្ធនាគារនីមួយៗ ត្រូវមានបញ្ជីជនជាប់ឃុំដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ជនជាប់ឃុំ ហើយចុះទិដ្ឋាការដោយតំណាងអង្គការអយ្យការនៅគ្រប់ទំព័រ ។

ចំពោះជនជាប់ឃុំជាស្ត្រីភេទ និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ ។

**មាត្រា ២២.-**

បញ្ជីជនជាប់ឃុំត្រូវបានត្រួតពិនិត្យដោយតំណាងអង្គការអយ្យការ និងត្រូវជូនទៅចៅក្រមពិនិត្យ មើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ២៣.-**

គ្រប់ពន្ធនាគារត្រូវបង្កើតសំណុំឯកសារផ្ទាល់ខ្លួន សម្រាប់ជនជាប់ឃុំម្នាក់ៗ រាប់ទាំងជនជាប់ឃុំជាអនីតិជនផង ។ ព័ត៌មាន និងឯកសារពាក់ព័ន្ធទាំងអស់របស់ជនជាប់ឃុំ ត្រូវរក្សាទុកជាការសម្ងាត់ក្នុងសំណុំរឿងផ្ទាល់ខ្លួន ។

**មាត្រា ២៤.-**

ជនជាប់ឃុំ ត្រូវបានពិនិត្យវាយតម្លៃសុខភាពដោយមន្ត្រីពេទ្យពន្ធនាគារ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងជនជាប់ឃុំ នូវព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬ ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

ក្នុងការចូលរួមការងារពលកម្មក្នុងពន្ធនាគារ ពេលពិនិត្យវាយតម្លៃសុខភាពលើកដំបូង មន្ត្រីពេទ្យពន្ធនាគារត្រូវកំណត់អំពីសមត្ថភាពកាយសម្បទា និងត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងផ្ទាល់ខ្លួនរបស់ទណ្ឌិត ដោយត្រូវយកចិត្តទុកដាក់ដល់សេចក្តីត្រូវការជាក់លាក់ និងខុសៗគ្នារបស់ស្ត្រី និងអនីតិជន ។

**មាត្រា ២៥.-**

រាល់ការធ្វើទារុណកម្ម ទង្វើអមនុស្សធម៌ ឬការប្រើប្រាស់ឧបករណ៍ផ្សេងៗ ដើម្បីដាក់ទណ្ឌកម្មដល់ជនជាប់ឃុំ ត្រូវហាមឃាត់ លើកលែងតែខ្នោះដៃដែលត្រូវបានអនុញ្ញាតតាមមាត្រា ៥០ នៃច្បាប់នេះ ។

**មាត្រា ២៦.-**

ជនជាប់ឃុំជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជន ត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត ។

ជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកពីជនជាប់ឃុំជាបុរស ។

ជនជាប់ឃុំជាអនីតិជន ត្រូវដាក់បំបែកពីជនជាប់ឃុំជានីតិជន ។

ជនជាប់ឃុំដែលមានជំងឺឆ្លង ត្រូវដាក់បំបែកចេញពីជនជាប់ឃុំដទៃទៀត ។

**មាត្រា ២៧.-**

ក្រោយពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារត្រូវចាត់ឲ្យមានការវាយតម្លៃ កំណត់អំពីចំណាត់ថ្នាក់សន្តិសុខ ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងពន្ធនាគារ ។

## ជំពូកទី ៥
## សិទ្ធិ និងលក្ខខណ្ឌរស់នៅរបស់ជនជាប់ឃុំ

**មាត្រា ២៨.-**

ជនជាប់ឃុំ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ជនជាប់ឃុំដូចគ្នា ឬអំពើរំលោភរបស់មន្ត្រីពន្ធនាគារ ។

ពាក្យបណ្តឹងតវ៉ារបស់ជនជាប់ឃុំ ត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ ឬអ្នកសួរសុខទុក្ខផ្លូវការ ឬអ្នកសួរសុខទុក្ខសាច់ញាតិ ឬមេធាវីរបស់ជនជាប់ឃុំ ឬតំណាងអង្គការអយ្យការ ។

រាល់បណ្តឹងតវ៉ាត្រូវតែបានដោះស្រាយនិងឆ្លើយតប ក្នុងរយៈពេលសមស្រប ។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម ឬត្រូវបានរើសអើងដោយសារតែបានដាក់ពាក្យបណ្តឹង ឬការដាក់ពាក្យស្នើសុំនោះឡើយ ។

**មាត្រា ២៩.-**

ជនជាប់ឃុំមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខិតបង្ខំឲ្យប្រតិបត្តិសាសនាណាមួយឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៣០.-**

ជនជាប់ឃុំដែលមិនតម្រូវឲ្យធ្វើការនៅខាងក្រៅបាន ដោយមូលហេតុខាងផ្លូវច្បាប់ ឬមូលហេតុខាងសន្តិសុខ អាចអនុញ្ញាតឲ្យធ្វើលំហាត់ប្រាណប្រចាំថ្ងៃបាន ។

**មាត្រា ៣១.-**

ជនជាប់ឃុំជាជនបរទេស មានសិទ្ធិទាក់ទងជាមួយស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

រាល់ទំនាក់ទំនងរវាងជនជាប់ឃុំនិងមេធាវី ត្រូវបានធ្វើឡើងដោយសម្ងាត់ ។

**មាត្រា ៣២.-**

ជនជាប់ឃុំ មានសិទ្ធិទទួល និង ផ្ញើលិខិតឆ្លងឆ្លើយ ។ លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារ ដែលត្រូវបានប្រគល់សិទ្ធិ លើកលែងតែលិខិតរបស់មេធាវី ។

លិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំ ត្រូវបានដកហូត ប្រសិនបើមានការពាក់ព័ន្ធដល់សន្តិសុខសុវត្ថិភាព សណ្ដាប់ធ្នាប់ទូទៅ ទាំងក្នុង និងក្រៅពន្ធនាគារ ។

**មាត្រា ៣៣.-**

ជនជាប់ឃុំ ត្រូវបានទទួលរបបជីវភាព ដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៤.-**

ការផ្ដល់អាហារដល់ជនជាប់ឃុំ ត្រូវយកចិត្តទុកដាក់គិតគូរអំពីអាហារតម ស្របតាមតម្រូវការខាងសុខភាព ដែលបញ្ជាក់ពីមន្ត្រីពេទ្យពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ ។

ជនជាប់ឃុំ អាចទទួល ឬទិញអាហារដោយថវិកាផ្ទាល់ខ្លួនពីប្រភពខាងក្រៅបាន តែអាហារទាំងនេះត្រូវបានត្រួតពិនិត្យពីមន្ត្រីពន្ធនាគារ ។

**មាត្រា ៣៥.-**

ជនជាប់ឃុំ អាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ដើម្បីទិញសម្ភារៈប្រើប្រាស់ ឬទទួលសម្ភារៈប្រើប្រាស់ពីគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងទៀត ប្រសិនបើមានការយល់ព្រម និងការត្រួតពិនិត្យពីប្រធានពន្ធនាគារ ។

ជនជាប់ឃុំ មិនត្រូវបានអនុញ្ញាតឲ្យទិញ ឬផ្ដល់ ឬឲ្យខ្ចី ឬលក់សម្ភារៈទៅឲ្យជនជាប់ឃុំផ្សេងទៀតបានឡើយ ។

**មាត្រា ៣៦.-**

ថវិកា ឬទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំ ត្រូវបានដកហូត កត់ត្រាត្រឹមត្រូវ ក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារ ញាតិមិត្តរក្សាទុក ប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំ ដោយត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ឃុំ ។

ក្នុងករណីចាំបាច់និងមានការយល់ព្រមពីប្រធានពន្ធនាគារ ជនជាប់ឃុំអាចប្រើប្រាស់ថវិកាបញ្ញើរបស់ខ្លួនបាន ។

ថវិកា និងទ្រព្យសម្បត្តិមានតម្លៃរបស់ជនជាប់ឃុំដែលពន្ធនាគារទទួលខុសត្រូវរក្សាទុក ត្រូវប្រគល់ជូនជនជាប់ឃុំវិញ នៅពេលដោះលែង ។

ជនជាប់ឃុំអាចរក្សាទុកឱសថជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន ក្នុងករណីមានការយល់ព្រមពីមន្ត្រីពេទ្យពន្ធនាគារ ។

**មាត្រា ៣៧.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន និងទំនាក់ទំនងទូរសព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ ។

ជនជាប់ឃុំ អាចអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង ។

ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនឹងជំងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឲ្យបានដឹងទៅវិញទៅមក ។

**មាត្រា ៣៨.-**

ជនជាប់ឃុំដែលមានជំងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ ។

ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច ។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើរបស់ជនជាប់ឃុំ ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាល ត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ ។

**មាត្រា ៣៦.-**

ថវិកា ឬទ្រព្យសម្បត្តិមានតម្លៃជាប់ខ្លួនរបស់ជនជាប់ឃុំ ត្រូវបានដកហូត កត់ត្រាត្រឹមត្រូវ ក្នុងសៀវភៅបញ្ជី និងរក្សាទុកក្នុងគណនីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារ ញាតិមិត្តរក្សាទុក ប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំ ដោយត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ឃុំ ។

ក្នុងករណីចាំបាច់និងមានការយល់ព្រមពីប្រធានពន្ធនាគារ ជនជាប់ឃុំអាចប្រើប្រាស់ថវិកាបញ្ញើរបស់ខ្លួនបាន ។

ថវិកា និងទ្រព្យសម្បត្តិមានតម្លៃរបស់ជនជាប់ឃុំដែលពន្ធនាគារទទួលខុសត្រូវរក្សាទុក ត្រូវប្រគល់ជូនជនជាប់ឃុំវិញ នៅពេលដោះលែង ។

ជនជាប់ឃុំអាចរក្សាទុកឱសថជាកម្មសិទ្ធិផ្ទាល់ខ្លួនបាន ក្នុងករណីមានការយល់ព្រមពីមន្ត្រីពេទ្យពន្ធនាគារ ។

**មាត្រា ៣៧.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យទទួលដំណឹង ឬព័ត៌មានសំខាន់ៗ តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន និងទំនាក់ទំនងទូរសព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំឡើងដោយពន្ធនាគារ ។

ជនជាប់ឃុំ អាចអនុញ្ញាតឲ្យចូលសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឲ្យខ្ចីសៀវភៅយកទៅស្រាវជ្រាវនៅក្នុងបន្ទប់ឃុំឃាំងដើម្បីបង្កើនចំណេះដឹង ។

ពន្ធនាគារត្រូវជូនដំណឹងទាក់ទងនឹងជំងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឲ្យបានដឹងទៅវិញទៅមក ។

**មាត្រា ៣៨.-**

ជនជាប់ឃុំដែលមានជំងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពេទ្យពន្ធនាគារ ។

ជនជាប់ឃុំមានជំងឺធ្ងន់ ហើយតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យខាងក្រៅតាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ច ។ ក្នុងករណីជនជាប់ឃុំមានជំងឺធ្ងន់ ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរបស់មន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ព្រះ-រាជអាជ្ញាក្នុងដែនសមត្ថកិច្ច និងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុត តាមសំណើរបស់ជនជាប់ឃុំ ។ បន្ទាប់ពីការព្យាបាលបានធូរស្រាល តាមការបញ្ជាក់ពីមន្ទីរពេទ្យដែលបានទទួលព្យាបាល ត្រូវបញ្ជូនជនជាប់ឃុំមកពន្ធនាគារវិញ ។

ជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ឬពិការកាយសម្បទា ឬស្ថិតក្រោមឥទ្ធិពលគ្រឿងញៀនត្រូវបានទទួលសេវាថែទាំសុខភាពដោយឡែក ។

**មាត្រា ៣៩.-**

អគារឃុំឃាំងជនជាប់ឃុំជាស្ត្រីត្រូវមានមន្ត្រីពន្ធនាគារជាស្ត្រី ប្រចាំការជាអចិន្ត្រៃយ៍ ។

មិនអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារជាបុរសចូលក្នុងតំបន់ជនជាប់ឃុំជាស្ត្រី ដោយគ្មានការអមដំណើរពីមន្ត្រីពន្ធនាគារជាស្ត្រីឡើយ លើកលែងតែក្នុងករណីមានឧប្បត្តិហេតុសង្គ្រោះបន្ទាន់ ឬក្នុងហេតុផលសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

**មាត្រា ៤០.-**

ជនជាប់ឃុំជាស្ត្រីត្រូវបានផ្តល់សេវាគាំពារមាតា និងទារក នៅមុននិងក្រោយពេលសម្រាលកូន ។

ជនជាប់ឃុំជាស្ត្រីដែលមានផ្ទៃពោះ ត្រូវបានអនុញ្ញាតឲ្យសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅ ។

ក្នុងករណីមានជនជាប់ឃុំជាស្ត្រីសម្រាលកូនក្នុងពន្ធនាគារ មិនត្រូវចុះសំបុត្រកំណើតថាទារកនោះកើតនៅក្នុងពន្ធនាគារទេ ។

**មាត្រា ៤១.-**

កូនតាមម្តាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយត្រឹមអាយុក្រោម ៣ (បី) ឆ្នាំ និងត្រូវបានផ្តល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព ។

កូនតាមម្តាយដែលមានអាយុចាប់ពី ៣ (បី) ឆ្នាំ ឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិ-សម្បទា ។

## ជំពូកទី ៦
## ការគ្រប់គ្រងពន្ធនាគារ

**មាត្រា ៤២.-**

គោលដៅជាសារវន្តនៃការគ្រប់គ្រងជនជាប់ឃុំ គឺការអប់រំកែប្រែនិងការស្តារនីតិសម្បទារបស់ជនជាប់ឃុំ ដែលជាស្នូលនៃក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ ។

ការដាក់វិន័យទៅលើជនជាប់ឃុំ ត្រូវធ្វើឡើងក្នុងកម្រិតអប្បបរមាដែលចាំបាច់ ដើម្បីធានាសន្តិ-សុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ ។

**មាត្រា ៤៣.-**

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវដោយផ្ទាល់ ក្នុងការគ្រប់គ្រងពន្ធនាគារឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៤.-**

មន្ត្រីពន្ធនាគារអាចធ្វើការឆែកឆេរជនជាប់ឃុំនិងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ ។

ជនជាប់ឃុំដែលបដិសេធមិនឲ្យមន្ត្រីពន្ធនាគារឆែកឆេរ ត្រូវចាត់ទុកជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ។

**មាត្រា ៤៥.-**

ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ពន្ធនាគារ មន្ត្រីពន្ធនាគារ និងអ្នកមកសួរសុខទុក្ខជនជាប់ឃុំ ត្រូវបានត្រួតពិនិត្យមុនពេលចូលទៅក្នុងពន្ធនាគារ ។

**មាត្រា ៤៦.-**

ការរក្សាទុក ឬការប្រើប្រាស់គ្រឿងស្រវឹងក្នុងពន្ធនាគារត្រូវហាមឃាត់ ។

ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឲ្យរក្សាទុក ឬប្រើប្រាស់វត្ថុទាំងឡាយណាដែលអាចគំរាមកំហែងដល់សន្តិសុខពន្ធនាគារឡើយ ។

ប្រភេទវត្ថុហាមឃាត់ត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

**មាត្រា ៤៧.-**

ប្រធានពន្ធនាគារអាចអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារដែលបានបណ្តុះបណ្តាលហ្វឹកហាត់ត្រឹមត្រូវឲ្យប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការរបស់ពន្ធនាគារ ។

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងអាវុធ និងឧបករណ៍បច្ចេកទេសឲ្យមានសុវត្ថិភាព ។

**មាត្រា ៤៨.-**

ប្រធានពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា គណៈអភិបាលរាជធានី ខេត្ត និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬដែលអាចគំរាមកំហែងដល់សន្តិសុខ សុវត្ថិភាពពន្ធនាគារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៩..**

ប្រធានពន្ធនាគារអាចប្រើប្រាស់កម្លាំងប្រតិបត្តិការដើម្បីរក្សាសន្តិសុខ សុវត្ថិភាពពន្ធនាគារ ។ ក្នុងករណីធ្ងន់ធ្ងរ ប្រធានពន្ធនាគារត្រូវរាយការណ៍សុំកម្លាំងអន្តរាគមន៍ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ។

**មាត្រា ៥០..**

ការប្រើប្រាស់ខ្នោះដៃដើម្បីដាក់ទណ្ឌកម្មជនជាប់ឃុំត្រូវហាមឃាត់ លើកលែងតែប្រើប្រាស់ក្នុងស្ថានភាពដូចខាងក្រោម :

- ពេលមានចលាចលក្នុងពន្ធនាគារ
- ពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ
- ពេលមានហេតុផលខាងពេទ្យ
- ដើម្បីការពារជនជាប់ឃុំកុំឲ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ។

**មាត្រា ៥១..**

ជនជាប់ឃុំត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងការណែនាំរបស់មន្ត្រីពន្ធនាគារ ។

**មាត្រា ៥២..**

ជនជាប់ឃុំដែលបានប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ពន្ធនាគារ មិនត្រូវលើកយកមកពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងរយៈពេលមួយឆ្នាំ ។ ក្នុងករណីមិនរាងចាល ត្រូវឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ។

ប្រធានពន្ធនាគារដែលចេញបទបញ្ជាឲ្យឃុំខ្លួននៅក្នុងបន្ទប់ដោយឡែក ត្រូវបញ្ជាក់ពីមូលហេតុ និងត្រូវរាយការណ៍ភ្លាមមកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។

បទបញ្ជាឃុំខ្លួនដោយឡែកអាចមានរយៈពេលពី ១៤ (ដប់បួន) ថ្ងៃ ដល់ ២០ (ម្ភៃ) ថ្ងៃ ។ ក្នុងករណីមិនរាងចាល បទបញ្ជានេះអាចត្រូវបានចេញបន្តទៀត ។

ក្នុងរយៈពេលនៃការរងទណ្ឌកម្មដោយត្រូវឃុំខ្លួនក្នុងបន្ទប់ដោយឡែក ជនជាប់ឃុំមិនត្រូវបានអនុញ្ញាត :

- ឲ្យជួបគ្រួសារសាច់ញាតិដែលមកសួរសុខទុក្ខ
- ចូលរួមសកម្មភាពផ្សេងៗក្នុងពន្ធនាគារ ។



**មាត្រា ៥៣.-**

ការធ្វើទារុណកម្មមកលើរាងកាយគ្រប់រូបភាព ការឃុំខ្លួនក្នុងបន្ទប់ងងឹត ការកាត់បន្ថយម្ហូបអាហារ ការដាក់ទណ្ឌកម្មជាសមូហភាពដល់ជនជាប់ឃុំ និងការប្រើប្រាស់ជនជាប់ឃុំឲ្យធ្វើទារុណកម្មជនជាប់ឃុំដូចគ្នា ត្រូវហាមឃាត់ ។

**មាត្រា ៥៤.-**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចពន្ធនាគារស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ បែបបទ នីតិវិធី និងការប្រព្រឹត្តទៅនៃការធ្វើអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

យន្តការបង្ការថ្នាក់ជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានា គ្រប់ពេលវេលា និងធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬ បន្ទាបបន្ថោក ។

**មាត្រា ៥៥.-**

ជនជាប់ឃុំត្រូវបានអនុញ្ញាតឲ្យគ្រួសារ ឬញាតិមិត្តមកសួរសុខទុក្ខតាមការកំណត់ លើកលែងតែមានការហាមឃាត់ពីអាជ្ញាធរតុលាការ ។

ប្រធានពន្ធនាគារត្រូវបិទផ្សាយជាសាធារណៈនូវពេលវេលា និងរយៈពេលសួរសុខទុក្ខ ដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ ។

**មាត្រា ៥៦.-**

មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជន ជាប់ឃុំជាពលរដ្ឋរបស់ខ្លួន ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាង ត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ ។

គ្រួសារ ឬញាតិមិត្តជាជនបរទេសដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំ ត្រូវស្នើមកអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន ។

**មាត្រា ៥៧.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ មិនត្រូវយកវត្ថុ ឬសម្ភារៈហាមឃាត់ ដូចមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងពន្ធនាគារចូលពន្ធនាគារឡើយ ។



**មាត្រា ៥៨.-**

អ្នកសួរសុខទុក្ខជនជាប់ឃុំ អាចត្រូវបានហាមឃាត់ ឬបញ្ឈប់ ឬឲ្យចេញជាបណ្ដោះអាសន្នពីពន្ធនាគារ ក្នុងករណីដែលមានឧប្បត្តិហេតុចៃដន្យកើតឡើង ។

ក្នុងករណីអ្នកសួរសុខទុក្ខជនជាប់ឃុំធ្វើសកម្មភាពនាំឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពពន្ធនាគារ ត្រូវឃាត់ខ្លួននិងចាត់វិធានការតាមផ្លូវច្បាប់ ។

**មាត្រា ៥៩.-**

បើអ្នកសួរសុខទុក្ខផ្លូវការមានបំណងធ្វើទស្សនកិច្ចពន្ធនាគារណាមួយ ត្រូវផ្ដល់ដំណឹងជាមុនទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អំពីគោលបំណង និងសំណូមពរនៃទស្សនកិច្ចនោះ ។

លទ្ធផលនៃទស្សនកិច្ចខាងលើ ត្រូវផ្ដល់ព័ត៌មានដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរទៅប្រធានពន្ធនាគារ និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ។ ព័ត៌មាននោះត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ លើកលែងតែមានការឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ជនជាប់ឃុំអាចត្រូវបានឲ្យចាកចេញជាបណ្ដោះអាសន្នពីពន្ធនាគារ តាមដីកាបង្គាប់របស់តុលាការ ដើម្បីឡើងសវនាការ ឬធ្វើការស៊ើបអង្កេត ឬចង្អុលបង្ហាញភស្តុតាង ។

**មាត្រា ៦១.-**

ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវអំពីសន្តិសុខ សុវត្ថិភាពចំពោះការនាំខ្លួន ឬការបញ្ជូនជនជាប់ឃុំទៅកាន់តុលាការ ឬទៅកាន់មន្ទីរពេទ្យខាងក្រៅ ។

**មាត្រា ៦២.-**

ការផ្ទេរបញ្ជូនទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជូនដំណឹងភ្លាម ឬយ៉ាងយូរ ៣ (បី) ថ្ងៃ ដោយប្រធានពន្ធនាគារទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងសមត្ថកិច្ចខាងដែនដីទទួល ។

ការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្ដី ។

ក្នុងករណីចាំបាច់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអាចចេញដីកាបង្គាប់ឲ្យផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ តាមតម្រូវការនៃនីតិវិធី ។ ដីកាបង្គាប់នេះត្រូវចម្លងជូនទៅក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE • LE MINISTRE du PALAIS ROYAL

ការផ្ទេរបញ្ជូនជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវភ្ជាប់ទៅជាមួយនូវទ្រព្យសម្បត្តិ សំណុំរឿង និងឯកសារសុខភាពរបស់ជនជាប់ឃុំ ។

**មាត្រា ៦៣.-**

ក្នុងករណីជនជាប់ឃុំលួចរត់គេចខ្លួន ប្រធានពន្ធនាគារ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងជាបន្ទាន់ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី ដើម្បីស្វែងរកចាប់ខ្លួនជនជាប់ឃុំមកវិញ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៦៤.-**

ក្នុងករណីជនជាប់ឃុំទទួលមរណភាពក្នុងពន្ធនាគារ ត្រូវចាត់ទុកជាការសង្ស័យ ។ មន្ត្រីពន្ធនាគារត្រូវការពារកន្លែងសាកសព និងរក្សាទុកជនជាប់ឃុំដែលអាចធ្វើសាក្សី ។ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីចាត់វិធានការស៊ើបអង្កេត ។

ប្រសិនបើជនជាប់ឃុំស្លាប់នៅក្នុងមន្ទីរពេទ្យ ប្រធានពន្ធនាគារត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា បើមានការសង្ស័យ ព្រះរាជអាជ្ញាត្រូវចាត់ឲ្យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រធ្វើការពិនិត្យសាកសព ។

**មាត្រា ៦៥.-**

ប្រធានពន្ធនាគារត្រូវជូនដំណឹងភ្លាមទៅគ្រួសារសព ឬស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងនៃសព ដើម្បីរៀបចំទុកដាក់សព ។

ក្នុងករណីគ្មានក្រុមគ្រួសារ ឬសាច់ញាតិ ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីស្ថានភាពនៃសព ជូនព្រះរាជអាជ្ញា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ និងមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានរបស់សព ។ ការចំណាយលើការរៀបចំទុកដាក់សពជាបន្ទុករបស់រដ្ឋដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការអប់រំ កែប្រែ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង ការស្ដារនីតិសម្បទាទណ្ឌិត

**មាត្រា ៦៦.-**

ទណ្ឌិតត្រូវបានចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីអប់រំច្បាប់និងសីលធម៌សង្គម ដែលបានរៀបចំឡើងនៅតាមពន្ធនាគារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

**មាត្រា ៦៧.-**

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ។

កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនឹងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៨.-**

ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថា មានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៦៩.-**

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗ ដើម្បីផ្តល់ឱកាសឲ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ។

**មាត្រា ៧០.-**

ទណ្ឌិតដែលចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានបំពាក់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពការងារ ក្នុងពេលបំពេញការងារ ។

**មាត្រា ៧១.-**

បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ អន្តរជាតិដើម្បីបង្កើតការងារ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
[illegible]

សម្រាប់កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផលឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៧២.-**

ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីគ្រប់គ្រងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៣.-**

មុនផុតរយៈពេលទទួលរងទោស ៦ (ប្រាំមួយ) ខែ ទណ្ឌិតត្រូវបានទទួលកម្មវិធីសមាហរណកម្មដែលរៀបចំដោយពន្ធនាគារ ដើម្បីឲ្យគេក្លាយជាពលរដ្ឋអាចរស់នៅក្នុងសង្គមជាតិនិងសហគមន៍មូលដ្ឋានបានល្អ ។

## ជំពូកទី ៨
## ការបន្ធូរបន្ថយទោស ការលើកលែងទោស
## និង ការដោះលែងទណ្ឌិត

**មាត្រា ៧៤.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះ ត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត | ជាអនុប្រធាន |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ | ជាសមាជិក |
| - អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំ កែប្រែសាមី | ជាអនុប្រធាន |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធាននាយកដ្ឋានអប់រំកែប្រែ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានប្រតិបត្តិ | ជាសមាជិក |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប | ជាសមាជិក |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ចំនួន០១ រូប | ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៦.-**

លក្ខណសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែគំនិតមារយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។

**មាត្រា ៧៧.-**

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន ។

**មាត្រា ៧៨.-**

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៧៩.-**

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ ក្រោយពីបានទទួលលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៨១.-**

ការធ្វើទារុណកម្ម អំពើឃោរឃៅ និងរាល់ទម្រង់ផ្សេងទៀតនៃការរំលោភបំពានដែលប្រព្រឹត្តទៅលើជនជាប់ឃុំ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨២.-**

ជនជាប់ឃុំដែលបានលួចរត់ចេញពីការឃុំខ្លួនតាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

អំពើរបស់មន្ត្រីពន្ធនាគារដែលទទួលឃុំបុគ្គលណាម្នាក់ ឬពន្យាររយៈពេលឃុំ ឬដោះលែងជនជាប់ឃុំដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។



## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៤.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធនាគារដែលបានអនុវត្តកន្លងមក នៅមានសុពលភាព រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមគោលការណ៍នៃច្បាប់នេះ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៨៥.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៦១ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម. ១២១១/០១៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ១០៧៥ ច.ល

[illegible]ចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

## កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដឹកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (ស្លាប់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្ដាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨-១០-២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 កូរ៉េ ផ្លើស ពណ៌ក្រហម ទៅឈ្មោះ ខ្ចីយកជិះទៅធ្វើសកម្មភាពគាស់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩-១០-២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០-១០-២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្ដង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូមខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាម៉ីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតម្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**************

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ . ភេទប្រុស <u>អាយុ ១៨ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរើសអេតចាយ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៣ និង ១៥ នាទីយប់រំលងអាធ្រាតចូលថ្ងៃទី ០៩.១០.២០១៥ ខ្ញុំបាទ និងបក្ខពួកប្អូននាក់ទៀតមានឈ្មោះ បង បង: បង ជិះម៉ូតូរ៉ឺម៉ក់អេតចាយ ទៅធ្វើសកម្មភាព គាស់សោរទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃប្រាកដមែន។ ហើយពួកខ្ញុំលួចបានទូដែកមួយមានប្រាក់ជាច្រើនមិនដឹងប៉ុន្មានទេ ហើយ ឈ្មោះ បានចែកប្រាក់អោយខ្ញុំបាទ ៦០០០ដុល្លារអាមេរិក ខ្ញុំបាទក៏បានផ្ញើទៅប្រពន្ធគាត់ ៨០០០ដុល្លារ ហើយទុក២០០០ដុល្លារចែកអ្នកជិតខាងផ្ទះៗ។ ចំពោះឯកសារនៅក្នុងទូដែកឈ្មោះ ចយ បានច្រកបាវ ដុតចោលអស់ហើយ ចំនែកទូដែក ខ្ញុំបាទពុំដឹងថានៅទីណាទេ។ រីឯអ្នកផ្សេងទៀត បានចំនែកម្នាក់[redacted]នៅប៉ុន្មានគឺឈ្មោះ យកទាំងអស់។

សួរ.ចម្លើយ៖ បក្ខពួករបស់ខ្ញុំខាងលើបានរត់គេចខ្លួនអស់ហើយ ខ្ញុំបាទពុំដឹងថាទៅទីណាទេ។

សួរ.ចម្លើយ៖ កន្លងមកខ្ញុំបាទធ្លាប់វាយសមត្ថកិច្ចប៉ូលីស ហើយត្រូវបានបញ្ជូមកសាលាដំបូងរាជធានីភ្នំពេញ និងប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្តាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្តិតស្រាមដៃជាមួយយើង។

**អ្នកឆ្លើយ** **ក្រឡាបញ្ជី** **ព្រះរាជអាជ្ញារង**

២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

ត-1292/02-12-2015

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខ 1324 អ.យ.ទ

## កំណត់ហេតុទទួលវត្ថុចាប់យក

ពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសាមសិប នាទី។

យើង ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាអ្នកទទួល។

លោក ជាមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ រួមជាមួយឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាជនសង្ស័យ។

បានពិនិត្យកិនកាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ឃើញដូចខាងក្រោម៖

✓១- ម៉ូតូមួយគ្រឿងម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់ ហើយមានតៃតួ)

២- ញញួរចំនួន០២, ដែកដាប់ចំនួន០៣, ដែកគាស់ចំនួន០១, កន្ត្រៃចំនួន០៦, កូនកាំបិតចំនួន០២, កាំបិតប៉ុងតោចំនួន០៤, ដាវចំនួន០១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន០១។

៣- អង្គចងចាំចំនួន០១។

យើងធ្វើកំណត់ហេតុនេះ ទុកជាភស្តុតាង ដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ តាមផ្លូវច្បាប់តទៅ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបី និងសែសិបប្រាំ នាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

| ជនជាប់សង្ស័យ | អ្នកប្រគល់ | អ្នកទទួល |
|---|---|---|

បានឃើញ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

## ឧបសម្ព័ន្ធទី៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ:៣៤៩៤ **<u>កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម</u>**
ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៦
លេខ:..............................អ.យ.រ

**ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែ កក្កដា ថ្ងៃទី ម្ភៃពីរ វេលាម៉ោង ដប់ប្រាំ និងសាមសិបនាទី។**

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ របាយការណ៍លេខ ២១៥/១៦ របក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

**បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម៖**

នាម-គោត្តនាម: ហៅ ភេទ ប្រុស អាយុ ២៦ឆ្នាំ (០៥-០២-១៩៩០) ជនជាតិ ខ្មែរ-ឥស្លាម កើតនៅសង្កាត់ ច្រាំងចំរេះទី១ ខណ្ឌ ឫស្សីកែវ ក្រុងភ្នំពេញ សាសនា ឥស្លាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២២៩ ផ្លូវលេខ ៥ សង្កាត់ ច្រាំងចំរេះទី២ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ លក់ហ្គាស់ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន-គ្មាន ជា-នីតិជន។

**យើងប្រាប់ដល់បុគ្គលនេះ នូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ៖**

-កាលពីថ្ងៃទី ២១ កក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មានករណីលួច នៅចំណុច ក្នុងហាងយីហោ យូឡោមី ផ្លូវ ២០១១ ភូមិ គោកឃ្លាង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ដែលបង្កដោយជនសង្ស័យម្នាក់ឈ្មោះ ហៅ ភេទ ប្រុស អាយុ ២៦ឆ្នាំ បានធ្វើសកម្មភាពលួចធុងហ្គាសពីទីតាំងខាងលើ ដែលពេលកំពុងធ្វើសកម្មភាពនោះ ម្ចាស់ហាងបានឃើញទាន់ ស្រែកថា "ចោរ"ៗ ហើយបុគ្គលិកក្នុងហាងក៏បាននាំគ្នារត់ដេញចាប់ជនសង្ស័យបាន ប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលភ្នំពេញថ្មីតែម្តង។

**អង្គហេតុនេះជាបទល្មើស៖** លួច ប្រព្រឹត្តនៅចំណុចក្នុងហាងយីហោ យូឡោមី ផ្លូវ ២០១១ ភូមិ គោកឃ្លាង សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

**យើងបានទទួលចម្លើយដូចតទៅ៖**

-ឈ្មោះ ភេទ ប្រុស អាយុ ៤៣ឆ្នាំ ជាដើមបណ្តឹងបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ ថា៖ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០១៦ វេលាម៉ោងប្រហែល ០៩ និង០០នាទី មុនពេលកើតហេតុ ខ្លួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

ដីកាលេខ ១៥១ "ញ"ព្រ.ទ
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

# ដីកាបង្គាប់ឲ្យឃុំខ្លួន

យើង **គាត សុគា** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត

- **បានឃើញ** មាត្រា ២០៦,២១៩,២២០,២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ៤០២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៣៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកំពត ដែលទាក់ទងនឹង៖

ជនត្រូវចោទឈ្មោះ **ជា សារ៉ែន** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌មធ្យមសិក្សាទុតិយភូមិ មុខរបរអគ្គនាយកក្រុមហ៊ុន ជាសារ៉ែន រៀលធី ទីកន្លែងកំណើតភូមិខ្ចល ឃុំល្បើក ស្រុកឈូក ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិខ្ចល ឃុំល្បើក ស្រុកឈូក ខេត្តកំពត មានប្រពន្ធឈ្មោះ **អៀម ចិន្តាស់** "រ" មានកូនចំនួន០២នាក់ ឪពុកឈ្មោះ **ជុំ គុន** "រ" ម្តាយឈ្មោះ **ឃឹម អ៊ីន** "ស" ជានិតិជន។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ឆបោកមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិបឹងនិមលនិងភូមិត្រពាំងបី ស្រុកឈូក ខេត្តកំពត និងភូមិព្រៃវែង ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត ចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន បទល្មើសមានចែង និងបញ្ញត្តឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧, មាត្រា៣៨០ នៃក្រមព្រហ្មទណ្ឌ។

- **បានឃើញ** ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ១៥០ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពត។

## បង្គាប់

១ - ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ **ជា សារ៉ែន** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ដែលមានសាវតារជាតិខាងលើ ទៅពន្ធនាគារខេត្តកំពត ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់។

២ - ឲ្យប្រធានពន្ធនាគារខេត្តកំពតទទួលនិងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣ - ឲ្យគ្រប់ភ្នាក់ងារ នៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឲ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
ធ្វើនៅកំពត,ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

គាត_សុគា

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត រាជធានី

សំណុំរឿងព្រហ្មទណ្ឌលេខ............

ចុះថ្ងៃទី..........................................

សំណុំរឿងស៊ើបសួរលេខ..................

ចុះថ្ងៃទី........................................

លេខ[1]........................................

# ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង.......................................ចៅក្រមស៊ើបសួរនៃសាលាដំបូង...........................អមដោយ លោក/លោកស្រី..............................................ជាក្រឡាបញ្ជី។

- បានឃើញមាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ............ចុះថ្ងៃទី.......ខែ........ឆ្នាំ............ ដែលបានបើកការស៊ើបសួរលើ

ឈ្មោះ.............................ឈ្មោះហៅក្រៅ.....................ភេទ.......ថ្ងៃខែឆ្នាំកំណើត.......................

សញ្ជាតិ...................មុខរបរ.........................មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ....................

កំរិតវប្បធម៌..............................ទីកន្លែងកំណើតនៅភូមិ...........................ឃុំ/សង្កាត់.......................

ស្រុក/ខណ្ឌ.........................ខេត្ត/រាជធានី..................................។

ទីលំនៅផ្ទះលេខ.......................ផ្លូវលេខ.................ភូមិ...........................ឃុំ/សង្កាត់......................

ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត................។

ឪពុកឈ្មោះ.....................................រ☐ ស☐ ម្ដាយឈ្មោះ.....................................រ☐ ស☐

ប្ដី/ប្រពន្ធឈ្មោះ..............................រ☐ ស☐ មានកូន.......នាក់ ឬនៅលីវ☐ នីតិជន☐ អនីតិជន☐។

មុខរបរ...........................................

---

[1] លេខរបស់ដីកាសម្រេច

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.............................................................................................។
ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ..................................តាមមាត្រា................................
នៃក្រមព្រហ្មទណ្ឌ/ច្បាប់...............................................................................................................។

ប្រព្រឹត្តនៅផ្ទះលេខ..............................ផ្លូវលេខ..............ភូមិ.......................ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ...................................ខេត្ត/រាជធានី.........................................................................
កាលពីថ្ងៃទី..................ខែ.................ឆ្នាំ.............។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

## I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១ ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ .........................ត្រូវចោទពីបទ...........................
(បញ្ចូលបទល្មើសដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ............)

២. ប្រព្រឹត្តិនៅ.........................................................................................................................
(សង្ខេបអង្គហេតុនៃរឿង)

៣. តំណាងអយ្យការ បានស្នើឲ្យឃុំខ្លួន☐ មិនឲ្យឃុំខ្លួន☐ បណ្តោះអាសន្នលើជនត្រូវចោទ ឈ្មោះ......................................ផ្អែកលើសំអាងហេតុដូចតទៅ...........................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

៤. ជនត្រូវចោទឈ្មោះ .......................................ឬមេធាវីការពារ ស្នើសុំ(កូនក្តីឲ្យ)នៅក្រៅឃុំ បណ្តោះអាសន្ន☐ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ☐ ដោយសំអាងហេតុផលថា
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

## II. សំអាងហេតុនៃសេចក្តីសម្រេច

៥. ជនត្រូវចោទឈ្មោះ.....................................ត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦. (បញ្ចូលនូវការយល់ឃើញឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលលើកឡើងដោយភាគីមានដូចជា តំណាងអយ្យការ និងជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ដោយពន្យល់សំអាងហេតុគាំទ្រទៅនឹងមូលហេតុនៃការឃុំខ្លួន ចំនួនមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)..............................................................................................

..............................................................................................

..............................................................................................

(ហេតុផលជាមូលដ្ឋានពីថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងមានយោងតាមបញ្ញត្តិច្បាប់)

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងអាចធានាឲ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ..............................ជាបណ្ដោះអាសន្នរយៈពេលអតិបរមា............។

ធ្វើនៅ..............ថ្ងៃទី........ខែ...........ឆ្នាំ..........

**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ចូល ថ្ងៃទី 12 ខែ 5 ឆ្នាំ 17

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៩៧៥
ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៧
លេខ: ១៤១៤២ អ.យ.រ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង **សេង ហៀង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៧៥ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ របាយការណ៍សំយោគលេខ ១៣៨/១៧ រ.ប.ក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

## ឃើញថា មានតម្រុយសន្និដ្ឋានថា៖

១-នាមត្រកូល-នាមខ្លួន ភេទ ប្រុស អាយុ ១៧ឆ្នាំ (២០-៤-២០០០) ជនជាតិខ្មែរ កើតនៅសង្កាត់ ទួលសង្កែ ខណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន ផ្ទះជួលគ្មានលេខ ផ្លូវ រទេះភ្លើង សង្កាត់ ទួលសង្កែ ខណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញ មុខរបរ សិស្សថ្នាក់ទី៩ នៅលីវ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ទោសពីមុន-គ្មាន ជាអនីតិជន។ (ឃាត់ខ្លួន)

២-ឈ្មោះ ភេទ ប្រុស អាយុប្រហែល ២៧ឆ្នាំ។ (គេចខ្លួន)

## បានប្រព្រឹត្តអំពើដូចតទៅ[២]៖

កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ វេលាម៉ោង ០៣និង៣០នាទីរំលងអាធ្រាត្រ នៅចំណុចមុខផ្ទះលេខ ៣៥អឺ០ ផ្លូវ ៣០៤ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ មានករណីលួច (ប៉ុនប៉ង) មួយបានកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ ភេទ ប្រុស អាយុប្រហែល ២៧ឆ្នាំ និងឈ្មោះ ភេទ ប្រុស អាយុ ១៧ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ ស៊េរី២០១៧ ពាក់ស្លាកលេខ ភ្នំពេញ GG-8403 ធ្វើសកម្មភាពឆក់កាបូបពីជនរងគ្រោះ ដោយឈ្មោះ ជាអ្នកលូកដៃឆក់កាបូប តែជនរងគ្រោះបានដឹងខ្លួនទាន់ ទាញកាបូបមកវិញ ហើយស្រែកចោរៗ ផ្អើលដល់សមត្ថកិច្ចល្បាតបានមកអន្តរាគមន៍ទាន់ពេលឃាត់បានជនសង្ស័យឈ្មោះ រួមទាំងវត្ថុតាង បញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌចំការមន ដើម្បីចាត់ការតាមនីតិវិធី ចំណែកជនសង្ស័យឈ្មោះ បានរត់គេចខ្លួនបាត់។

[២] សេចក្ដីសង្ខេបអង្គហេតុ

អំពើខាងលើជាបទល្មើស *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

## <u>ហេតុដូច្នេះសម្រេច</u>

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ ដាក់អោយស្ថិតនៅក្រោមការពិនិត្យ[៣]៖

១-ឈ្មោះ ភេទ ប្រុស អាយុ ១៧ឆ្នាំ។ (ឃាត់ខ្លួន)

២-ឈ្មោះ ភេទ ប្រុស។ (គេចខ្លួន)

ពីបទ *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ តាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៤]៖

-ឈ្មោះ ភេទ ប្រុស អាយុ ១៧ឆ្នាំ។ (ឃាត់ខ្លួន)

ពីបទ *លួច (ប៉ុនប៉ង)* ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ផ្លូវលេខ ក្រុមទី ៤១ ភូមិ ៥ សង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៧ តាមមាត្រា ៣៥៣, មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ៕

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ ឧសភា ឆ្នាំ២០១៧

ព្រះរាជអាជ្ញា

សេង ហៀង

ព្រះរាជអាជ្ញារង

[៣] ឈ្មោះជនត្រូវចោទ

**ឧបសម្ព័ន្ធទី៥**

ខាវ៉ែម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦៧
ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧
លេខ:...........................អ.យ.រ

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៨៦៧ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្តឹងផ្ទាល់ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧ របស់ដើមបណ្តឹងឈ្មោះ ភេទ ប្រុស អាយុ ៣៦ឆ្នាំ បានប្តឹងចោទប្រកាន់លើឈ្មោះ ភេទ ប្រុស និងឈ្មោះ ភេទ ស្រី អាយុ ៥៧ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្មតបានថា៖**

-នាមត្រកូល-នាមខ្លួន ភេទ ស្រី អាយុ ៥៧ឆ្នាំ (០២-៧-១៩៥៩) ជនជាតិ ខ្មែរ កើតនៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៧៩ង ផ្លូវ លំ ក្រុម ២ ភូមិ ស្លែងរលើង សង្កាត់ ទឹកថ្លា ខណ្ឌ សែនសុខ រាជធានីភ្នំពេញ មុខរបរ មន្ត្រីសុខាភិបាលនៅមន្ទីរពេទ្យកុមារជាតិ ប្តីឈ្មោះ (លែងលះ) -រ- មានកូន ០៤នាក់ ឪពុកឈ្មោះ -ស- ម្តាយឈ្មោះ -រ- ទោសពីមុន-គ្មាន ជា-នីតិជន។ (ក្រៅឃុំ)

**បានប្រព្រឹត្តអំពើដូចតទៅ[២]៖**

កាលពីអំឡុងខែ កញ្ញា ឆ្នាំ២០១៦ ឈ្មោះ បានផ្ញើរប្រាក់ចំនួន០២ពាន់ដុល្លារ ឲ្យទៅមិត្តភក្តិឈ្មោះ ដែលរស់នៅប្រទេសជប៉ុនដើម្បីទិញឥវ៉ាន់មកឲ្យខ្លួនរួមមាន: កៅអីម៉ាស្សា០១គ្រឿង, កៅអីសម្រាប់ឃោលទារក០១គ្រឿង, ពោងសម្រាប់ក្មេងហែលទឹក០១, ឡាំងទឹក Sauce, អាហារកញ្ចប់, ឱសថបុរាណ, ម្ហូបកូនក្មេង, រថយន្តម៉ាកនីសាន់០១គ្រឿង ព្រមទាំងសំភារៈប្រើប្រាស់មួយចំនួនទៀត។ បន្ទាប់ពីឈ្មោះ បានប្រគល់ប្រាក់ឲ្យទៅឈ្មោះ រួចមកឈ្មោះ បានប្រាប់ទៅឈ្មោះ វិញថា ឥវ៉ាន់ទាំងអស់ខាងលើនេះនឹងរៀបចំផ្ញើរមកឲ្យ តាមរយៈឈ្មោះ និងម្តាយឈ្មោះ ហើយនៅពេលដែលអ្នកទាំងពីរបានទទួលឥវ៉ាន់ទាំងអស់ខាងលើនេះ ហើយ ឈ្មោះ និងឈ្មោះ នឹងទាក់ទងមកឈ្មោះ ដើម្បីទៅទទួលឥវ៉ាន់ទាំង

[២] សេចក្តីសង្ខេបអង្គហេតុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ..300..“ឡ” ដ.ច.ខ

# ដីកាបង្គាប់ចាប់ខ្លួន

យើង ជុំ សឡា ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥១៩៩ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៩៨៩ “ឡ” ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ គួច ចឹង អេច ប្រុស កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ជនជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ ចំនួន ៥,០០០,០០០ ៛ (ប្រាំលាន)រៀល ពីបទ ក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៦២៦, មាត្រា ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ និងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១- ឲ្យចាប់ខ្លួនឈ្មោះ គួច ចឹង អេច ប្រុស កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ជនជាតិខ្មែរ មុខរបរ នៅផ្ទះមើលចៅ ទីកន្លែងកំណើតភូមិចុងព្រៃ ឃុំចុងព្រៃ ស្រុកច្បូរ ខេត្តព្រះត្រពាំង កម្ពុជាក្រោម ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២៧៣៥ ផ្លូវលំ ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម៉ៅ គួច “ស្លាប់” ម្តាយឈ្មោះ គឹម ហៀង “ស្លាប់” ប្រពន្ធឈ្មោះ ហាញ់ សុវណ្ណា មានកូន ០៥នាក់ ជានីតិជន ។

២- បញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និង ឃុំខ្លួនជនជាប់ចោទខាងលើនេះ នៅមណ្ឌលអប់រំកែប្រែទី ១ (ម១) នៃក្រសួងមហាផ្ទៃ តាមអំណាចសាលក្រមនេះ ។

ថ្ងៃសុក្រ ០៣ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២៣
ចៅក្រមជំនុំជម្រះ

ជុំ_សឡា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
បន្ទប់ស៊ើបសួរ "ង"
សំណុំរឿងព្រហ្មទណ្ឌលេខ:២២៩
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣
សំណុំរឿងស៊ើបសួរលេខ:១៧៣
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣
លេខ: ២១៧

## <u>ដីកាបង្គាប់ឲ្យចាប់ខ្លួន</u>

យើង **សំ ប៊ុនពៅ** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ។

ដោយមានលោក **ឈិន សោភ័ណ្ឌ** ជាក្រឡាបញ្ជីអមផង។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:១៧៧ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយលេខ:៧០៦៩ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ និងយោបល់ឯកភាពរបស់លោកតំណាងអយ្យការ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយឃើញថា:**

ឈ្មោះ **ជា វិចិត្រ** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ។ ទីកន្លែងកំណើតនៅភូមិកែវឧត្តម ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ទីលំនៅបច្ចុប្បន្នភូមិកែវឧត្តម ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ ឪពុកឈ្មោះ ពៅ ចយ (រ) ម្តាយឈ្មោះ អ៊ុន ស៊ីមន (រ) ប្រពន្ធឈ្មោះ វី (រ) ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានចោទប្រកាន់ពីបទ: **លួច** ប្រព្រឹត្តនៅភូមិទី៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ។

**<u>យល់ឃើញថា:</u>**

-ជនត្រូវចោទឈ្មោះ **ជា វិចិត្រ** ភេទប្រុស អាយុ៣៨ឆ្នាំ ត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

-ជនត្រូវចោទឈ្មោះ **ជា វិចិត្រ** ភេទប្រុស អាយុ៣៨ឆ្នាំ ក្រោយពេលប្រព្រឹត្តបទល្មើសបានរត់គេចខ្លួនមិនដឹងស្ថិតនៅកន្លែងណា និងមានសាវតាជាតិគ្រប់គ្រាន់។

-គប្បីចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទឈ្មោះ **ជា វិចិត្រ** ភេទប្រុស អាយុ៣៨ឆ្នាំ។

**<u>ហេតុដូច្នេះសម្រេច</u>**

១/បង្គាប់ទៅភ្នាក់ងារមានសមត្ថកិច្ចឲ្យចាប់ខ្លួនឈ្មោះ **ជា វិចិត្រ** ភេទប្រុស អាយុ៣៨ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើនេះ មកប្រគល់ជូនតុលាការ សាមីចាត់ការតាមច្បាប់។

**២/បង្គាប់ឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ខេត្ត-រាជធានី ឲ្យទទួលនិងឃុំខ្លួនឈ្មោះ ខាងលើតាមដីកាបង្គាប់ឲ្យចាប់ខ្លួននេះ។**

បុគ្គលដែលត្រូវបានឃុំខ្លួននេះ ត្រូវនាំមកបង្ហាញខ្លួនដល់តុលាការដើម្បីចាត់ការបន្តក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមមាត្រា ២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ធ្វើនៅខេត្តកំពង់ស្ពឺ,ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

**ចៅក្រមស៊ើបសួរ**

សំ ប៊ុនពៅ